# ក

# មាតិកា

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


១៨-០១-២០០៨ -ព្រះរាជក្រម នស/រកម/០១០៨/០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ៨១០


### ២. ព្រះរាជក្រឹត្យ


១៨-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៤៦ ស្តីពីការបន្ថយរយៈពេលទទួលរងទោស និងលើកលែងទោសឱ្យទណ្ឌិតចំនួន ១៩៤ នាក់ ៨១៩

១៨-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៤៧ ស្តីពីការតែងតាំងលោក **លឹម ហ៊ួរនីតា** ជាឧកញ៉ា ៨៤៥

១៨-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៤៨ ស្តីពីការតែងតាំងលោក **ឈាង សុធី** ជាឧកញ៉ា ៨៤៦

១៩-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៤៩ ស្តីពីការតម្លើងឋានៈឯកឧត្តម **ខៀវ ឆេង** ជំនួយការឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ មានឋានៈស្មើអគ្គនាយក ៨៤៧

១៩-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៥០ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះឯកឧត្តម លោកឧកញ៉ា ចំនួន ០៤ រូប ៨៤៨

១៩-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៥៣ ស្តីពីការបញ្ចប់មុខតំណែងឯកឧត្តម **គឹម សុខុន** ពីទីប្រឹក្សា ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី និង ត្រូវបានតែងតាំងឯកឧត្តម **ខុន សំា** ឋានៈស្មើ រដ្ឋលេខាធិការ ជំនួសវិញ ៨៤៩

២៣-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៥៤ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តមឧកញ៉ា **ចក់ ឡេង** នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ៨៥០

២៣-០១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/០១០៨/០៥៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេនា ចំពោះ ០៥ ក្រុមហ៊ុន ៨៥១


## II. រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៨-០១-២០០៨ -អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពីការធ្វើអនុបយោគ និងការប្រគល់សិទ្ធិកាន់កាប់ដីស្ថិតនៅភូមិពូធឿន សង្កាត់បិតត្រាង និងភូមិស្ទាច់ដែន សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ៨៥២

២៨-០១-២០០៨ -អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្តីពីការកែសំរួលប្តូរឈ្មោះនាយកដ្ឋានព័ត៌មានទូទៅ ទៅជា នាយកដ្ឋានសន្តិសុខផ្ទៃក្នុង នៃក្រសួងមហាផ្ទៃ ៨៥៥

២៩-០១-២០០៨ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានចំណុះលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ៨៥៦

២៩-០១-២០០៨ -អនុក្រឹត្យលេខ ១០ អនក្រ.បក ស្តីពីការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ៨៦៥

២៩-០១-២០០៨ -អនុក្រឹត្យលេខ ១១ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ជាតិនៃប្រាសាទព្រះវិហារ ៨៦៧

៣០-០១-២០០៨ -អនុក្រឹត្យលេខ ១២ អនក្រ.បក ស្តីពីការធ្វើអនុបយោគ ទីតាំងមន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង ទីតាំងមន្ទីរអប់រំ យុវជន និង កីឡា ខេត្តបាត់ដំបង និងទីតាំង កងវរៈសេនាតូចលេខ ៥១២ ចំណុះកងពលតូចថ្មើរជើងលេខ ៥១ ៨៧៩

៣០-០១-២០០៨ -អនុក្រឹត្យលេខ ១៣ អនក្រ.បក ស្តីពីការបង្កើតក្រុមវិភាគព័ត៌មាន ៨៨១

២៥-០១-២០០៨ -អនុក្រឹត្យលេខ ៧៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៨៣

២៨-០១-២០០៨ -អនុក្រឹត្យលេខ ៧៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ៨៩២

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៧៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៩៣

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៧៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៩៥

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៧៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៩៧

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៩០០

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩០១

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩០៤

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩១១

២៩-០១-២០០៨ -អនុក្រឹត្យលេខ ៨២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩១៦

៣០-០១-២០០៨ -អនុក្រឹត្យលេខ ៨៣ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង នាយនគរបាលជាតិ ៩២០

៣០-០១-២០០៨ -អនុក្រឹត្យលេខ ៨៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩២១

៣០-០១-២០០៨ -អនុក្រឹត្យលេខ ៨៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩២២

# គ

## III-ការងារបណ្ដាក្រសួង

## ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៩-៤-២០០៨ -លិខិតបញ្ជាក់លេខ ១៤០១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្វារ លីន (ខេមបូឌា) អ៊ិនធើណេ សិនណាល អ៊ិនស៊ីរេន** ៩២៣

០៩-៤-២០០៨ -លិខិតបញ្ជាក់លេខ ១៤០៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជុង ឡៀន យ៉ាញ-ស្តុក ខមភេនី** ៩២៥

០៩-៤-២០០៨ -លិខិតបញ្ជាក់លេខ ១៤០៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ អិម អេស ខូ អិលធីឌី** ៩២៧

០៩-៤-២០០៨ -លិខិតបញ្ជាក់លេខ ១៤០៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.អេស.អិន.** ៩២៩

០៩-៤-២០០៨ -លិខិតបញ្ជាក់លេខ ១៤០៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី អិម ជី គ្លូប៊ល មេឌា គ្រុប** ៩៣១

នស/រកម/០១០៨/០០១

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈសមាជិកព្រឹទ្ធសភា

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់នូវអភ័យឯកសិទ្ធិសភា ឋានៈ បុព្វសិទ្ធិ វិសមិតភាព និង ល័ក្ខខ័ណ្ឌចាំបាច់នានា ដើម្បីធានាជូនដល់សមាជិកព្រឹទ្ធសភា ក្នុងការបំពេញភារកិច្ចស្រប តាមរដ្ឋធម្មនុញ្ញ ច្បាប់ និង លិខិតបទដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

សមាជិកព្រឹទ្ធសភាក្នុងព្រឹទ្ធសភា គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់ តែជាតំណាងឱ្យភូមិភាគរបស់ខ្លួននោះទេ ។

**មាត្រា ៣.-**

សមាជិកព្រឹទ្ធសភាមានអាណត្តិ ៦ ឆ្នាំ (ប្រាំមួយឆ្នាំ)ហើយត្រូវផុតកំណត់នៅពេលសមា- ជិកព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

## ជំពូកទី ២

## អភ័យឯកសិទ្ធិសភា

**មាត្រា ៤.-**

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។ អភ័យឯកសិទ្ធិសភា ត្រូវបានបែកចេញ ជាពីរផ្នែក :

-ការធានាក្នុងការបញ្ចេញយោបល់ ឬ ការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយ របស់សមាជិកព្រឹទ្ធសភា នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាសមាជិកព្រឹទ្ធសភា គឺជា អភ័យឯកសិទ្ធិដាច់ខាត ។

-ការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ឬ ការឃុំខ្លួនសមាជិកព្រឹទ្ធ- សភាណាមួយ គឺជាអភ័យឯកសិទ្ធិដោយប្រៀប ។

**មាត្រា ៥.-**

សមាជិកព្រឹទ្ធសភា មិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភ នាំឱ្យប៉ះពាល់ ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

**មាត្រា ៦.-**

សមាជិកព្រឹទ្ធសភា ត្រូវគោរពបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.-**

សមាជិកព្រឹទ្ធសភាដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនឹងអាចអនុញ្ញាតបើកឱ្យធ្វើ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមាន ការលើកអភ័យឯកសិទ្ធិសភាជាមុនសិន ។

**មាត្រា ៨.-**

សេចក្តីស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់សមាជិកព្រឹទ្ធសភារូបណាមួយ ត្រូវធ្វើឡើង ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់ សេចក្តីថ្លែងហេតុមកជាមួយផង ផ្ញើជូនប្រធានព្រឹទ្ធសភា ។

**មាត្រា ៩.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំព្រឹទ្ធសភា ត្រូវអនុវត្តតាមនីតិវិធី ខាងក្រោមនេះ :

-ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់តាមការស្នើសុំពីប្រធាន ឬ ពីសមាជិកព្រឹទ្ធសភា ចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬ ពីប្រធានរដ្ឋសភា ។

-កូរ៉ុមប្រជុំលើសពី ពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

-ការអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១០.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងចន្លោះសម័យប្រជុំព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា ត្រូវប្រជុំ និងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

**មាត្រា ១១.-**

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១២.-**

ក្នុងករណីសមាជិកព្រឹទ្ធសភាណា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភាជាបន្ទាន់ ដើម្បីសម្រេច ។

**មាត្រា ១៣.-**

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយ ត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ១៤.-**

សមាជិកព្រឹទ្ធសភាដែលអភ័យឯកសិទ្ធិសភាត្រូវបានលើក ហើយស្ថិតក្នុងការចោទប្រកាន់របស់តុលាការ មានសិទ្ធិ និងបុព្វសិទ្ធិដូចសមាជិកព្រឹទ្ធសភាទូទៅ ។

សមាជិកព្រឹទ្ធសភាដែលស្ថិតក្នុងការចាប់ខ្លួន ឬ ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន ត្រូវបាត់បង់សិទ្ធិចូលរួមប្រជុំព្រឹទ្ធសភា និងគណៈកម្មការផ្សេងៗ ប៉ុន្តែមានសិទ្ធិទទួលប្រាក់បំណាច់ វៀរលែងតែប្រាក់បំណាច់ប្រជុំ ប្រាក់បេសកកម្ម និងប្រាក់ប្រេងឥន្ធនៈ ។

សមាជិកព្រឹទ្ធសភាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថា ជាទណ្ឌិតជាប់ពន្ធនាគារ ត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិកព្រឹទ្ធសភា ។

**មាត្រា ១៥.-**

សមាជិកព្រឹទ្ធសភារូបណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោស សមាជិកព្រឹទ្ធសភារូបនោះនឹងបានទទួលសុពលភាព អភ័យឯកសិទ្ធិសភា និងបុព្វសិទ្ធិឡើង

**មាត្រា ១៦.-**

សមាជិកព្រឹទ្ធសភាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថាជាជនគ្មានទោស សមាជិកព្រឹទ្ធសភានោះ ត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិសភានិងបុព្វសិទ្ធិឡើងវិញ ។

## ជំពូកទី ៣

## វិសមិតភាព

**មាត្រា ១៧.-**

អាណត្តិនៃសមាជិកព្រឹទ្ធសភាមានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

## ជំពូកទី ៤

## ប្រាក់បំណាច់ ឋានៈ និងបុព្វសិទ្ធិ

**មាត្រា ១៨.-**

ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

សមាជិកព្រឹទ្ធសភាមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា ។

សមាជិកព្រឹទ្ធសភាគ្រប់រូប ត្រូវបានទទួលនូវការធានារ៉ាប់រងសង្គម នៅក្នុងអាណត្តិរបស់ខ្លួន ។

ក្នុងករណីដែលសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្មនៅក្នុងអាណត្តិ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងដល់គ្រួសារសព រយៈពេលមួយឆ្នាំទៀត គិតចាប់ពីថ្ងៃទទួលអនិច្ចកម្ម ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាត្រូវរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបធានាជម្ងឺ របបប្រាក់សោធននិវត្តន៍ របបបេសកកម្ម និងល័ក្ខខ័ណ្ឌធ្វើការងាររបស់សមាជិកព្រឹទ្ធសភា ។

**មាត្រា ១៩.-**

សមាជិកព្រឹទ្ធសភាទទួលប្រាក់សោធននិវត្តន៍ ។

ប្រាក់សោធននិវត្តន៍របស់សមាជិកព្រឹទ្ធសភា បើកនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

ប្រាក់សោធននិវត្តន៍បើកបានតែមួយកន្លែងគត់ ។

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ត្រូវសម្រេចឱ្យសមាជិកព្រឹទ្ធសភាចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២០.-**

ល័ក្ខខ័ណ្ឌទាំងឡាយដែលអតីតសមាជិកព្រឹទ្ធសភាទទួលបានប្រាក់សោធននិវត្តន៍ :

ក-ជាអតីតសមាជិកព្រឹទ្ធសភា ជាអតីតសមាជិករដ្ឋសភាគិតចាប់តាំងពីឆ្នាំ១៩៩៣ មកដែលបានមកបំពេញការងារជាសមាជិកព្រឹទ្ធសភា ឬ ជាអតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញគិតចាប់តាំងពីឆ្នាំ ១៩៩៨ មកដែលបានមកបំពេញការងារជាសមាជិកព្រឹទ្ធសភា ។

ខ-មានអាយុចាប់ពី ៦០ (ហុកសិប)ឆ្នាំឡើង ។

គ-មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។

**មាត្រា ២១.-**

រូបមន្តសម្រាប់គណនា រៀបចំរបបសោធននិវត្តន៍របស់អតីតសមាជិកព្រឹទ្ធសភា ត្រូវផ្អែកលើប្រាក់បំណាច់សមាជិកព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងរយៈពេលមួយឆ្នាំរបស់សមាជិកព្រឹទ្ធសភាម្នាក់ៗនៃឆ្នាំចុងក្រោយកំណត់ស្មើនឹង ១០០ ٪(មួយរយភាគរយ) ។

ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ:

| | |
|---|---|
| -ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបានសន្ទស្សន៍ | ០,៥ ٪ |
| -លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ | ១ ٪ |
| -ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ | ២ ٪ |

-ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣ %

-ពី ១៦ ឆ្នាំ ឡើងទៅទទួលបានសន្ទស្សន៍ ៤ %

អតីតសមាជិកព្រឹទ្ធសភាទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព វៀរលែងតែត្រូវបានជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ។

**មាត្រា ២២.–**

អតីតសមាជិកព្រឹទ្ធសភាដែលមិនជាប់ឆ្នោតឡើងវិញ ក្រោយពីមានអាយុគ្រប់៦០(ហុកសិប) ឆ្នាំ អាចទទួលបានប្រាក់សោធននិវត្តន៍ ដោយបើកផ្តាច់ត្រឹមរយៈពេលតែមួយឆ្នាំគត់បាន ។

**មាត្រា ២៣.–**

សមាជិកព្រឹទ្ធសភាមានអ្នកជំនួយការផ្ទាល់មួយចំនួនដែលជួយធ្វើការងារ តាមល័ក្ខខ័ណ្ឌបុគ្គលិកជាប់កិច្ចសន្យាដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឯប្រាក់កម្រៃជាបន្ទុកថវិកាព្រឹទ្ធសភា ។

ដើម្បីមានភាពងាយស្រួលក្នុងការបំពេញការងារ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជួយដល់សមាជិកព្រឹទ្ធសភា តាមបែបបទកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ។

**មាត្រា ២៤.–**

សមាជិកព្រឹទ្ធសភាក្នុងតំណែងត្រូវទទួលបាននូវ :

-ប័ណ្ណសំគាល់អភ័យឯកសិទ្ធិ

-រូបសញ្ញាព្រឹទ្ធសភាសម្រាប់ពាក់លើអាវ

-រូបសញ្ញាបារមីរបស់ព្រឹទ្ធសភា

-ផ្លាករថយន្តព្រឹទ្ធសភា

-លិខិតឆ្លងដែនការទូតផ្ទាល់ខ្លួន សហព័ទ្ធ និងកូនអាយុក្រោម ១៨ ឆ្នាំ

-ឯកសណ្ឋានព្រឹទ្ធសភា

-គ្រឿងឥស្សរិយយសពីរដង ក្នុងមួយអាណត្តិ

-ការធានារ៉ាប់រងជម្ងឺនៅក្នុងមន្ទីរពេទ្យរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្រើថវិការបស់ព្រឹទ្ធសភា ។

**មាត្រា ២៥.-**

មន្ត្រីរាជការស៊ីវិល ឬ កងកម្លាំងប្រដាប់អាវុធ ដែលជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ត្រូវបានឡើងឋានន្តរសក្តិ ឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាព សម្រាប់ទទួលសោធន-និវត្តន៍ ។

**មាត្រា ២៦.-**

សមាជិក សមាជិកាព្រឹទ្ធសភាក្នុងតំណែងត្រូវបានទទួលងារជា ឯកឧត្តម ឬ លោកជំទាវ ។ អតីតសមាជិក សមាជិកាព្រឹទ្ធសភា ក្រោយពេលដែលបានបញ្ចប់អាណត្តិហើយត្រូវបានរក្សាងារជាឯកឧត្តមអតីតសមាជិកព្រឹទ្ធសភា ឬ លោកជំទាវអតីតសមាជិកាព្រឹទ្ធសភា ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកម.០១០៨.០៣៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៦១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៨

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុត ជិនកេន**

T-2

នស/រកត/០១០៨/០៤៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ៣៥ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១- **ទណ្ឌិតឈ្មោះ អំប្រ៊ុច ឆាន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-១៩៩៥ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១-១២-១៩៩៥ របស់តុលាការខេត្តក្រចេះ ។

២- **ទណ្ឌិតឈ្មោះ អំប្រ៊ុច អាន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-១៩៩៥ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ០១-១២-១៩៩៥ របស់តុលាការខេត្តក្រចេះ ។

ROYAUME DU CAMBODGE ROYAL

៣. **ទណ្ឌិតឈ្មោះ ខៀវ ពៅ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-០២-១៩៩៧ ពីបទប្លន់សម្លាប់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី ២៣-៩-១៩៩៧ របស់តុលាការខេត្តកំពត។

៤. **ទណ្ឌិតឈ្មោះ កែវ ពិសិដ្ឋ** ហៅ ធី ហៅ ក្អួច សំណាង ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-០២-២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០២ ចុះថ្ងៃទី ០៧-៨-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង។

៥. **ទណ្ឌិតឈ្មោះ ម៉ាត់ សឿន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-០២-២០០១ ពីបទសម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៤ ចុះថ្ងៃទី ០៧-៨-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង។

៦. **ទណ្ឌិតឈ្មោះ ទ័ន យ៉េន** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-១១-១៩៩៧ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ និងសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ០២-៣-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង។

៧. **ទណ្ឌិតឈ្មោះ សោម សារឿន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៩-២០០២ ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៨-០២-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង។

៨. **ទណ្ឌិតឈ្មោះ កែម មិន** ភេទស្រី អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-១០-១៩៩៩ ពីបទអំពើពង្រាត់ និងលក់ដូរមនុស្ស និងធ្វើអាជីវកម្មលើមនុស្សអនិតិជន អាយុតិចជាង ១៥ ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ ចុះថ្ងៃទី ០៥-៤-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង។

៩. **ទណ្ឌិតឈ្មោះ ជៀម ចក់** ភេទប្រុស អាយុ ៥៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៦-១៩៩៨ ពីបទសមគំនិតសម្លាប់មនុស្ស ប្លន់ទ្រព្យសម្បត្តិប្រជាជន ក្រុមជនប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ ចុះថ្ងៃទី ២៦-១០-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង។

១០. **ទណ្ឌិតឈ្មោះ តិន ប៊ុនថា** ភេទប្រុស អាយុ ៤៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៦-១៩៩៨ ពីបទសមគំនិតសម្លាប់មនុស្ស ប្លន់ទ្រព្យសម្បត្តិប្រជាជន ក្រុមជនប្រដាប់អាវុធ និងប្រើប្រាស់

អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ៧០ ចុះថ្ងៃទី ២៦-១០-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១១. ទណ្ឌិតឈ្មោះ នៅ សុខ** ភេទប្រុស អាយុ ៥២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៦-១៩៩៨ ពីបទសមគំនិតសម្លាប់មនុស្ស ប្លន់ទ្រព្យសម្បត្តិប្រជាជន ក្រុមជនប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ៧០ ចុះថ្ងៃទី ២៦-១០-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១២. ទណ្ឌិតឈ្មោះ អឿន វណ្ណៈ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១១-១៩៩៩ ពីបទប្លន់ទ្រព្យសម្បត្តិ និងសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ០៨-៥-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៣. ទណ្ឌិតឈ្មោះ សួន សុវៀត** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-០២-១៩៩៩ ពីបទអំពើមនុស្សឃាតដោយចេតនា និងអំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ ចុះថ្ងៃទី ១៣-៧-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៤. ទណ្ឌិតឈ្មោះ ហ៊ុយ ហៀក** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-៩-១៩៩៩ ពីបទប្លន់ និងសម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១០-០១-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៥. ទណ្ឌិតឈ្មោះ ឃិន ជឿន** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-១១-១៩៩៩ ពីបទប្លន់ និងសម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១០-០១-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៦. ទណ្ឌិតឈ្មោះ ហែម ជឹម** ភេទប្រុស អាយុ ៥៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៩-១៩៩៥ ពីបទអំពើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧១ ចុះថ្ងៃទី ១៦-១២-១៩៩៥ របស់តុលាការខេត្តស្វាយរៀង ។

**១៧. ទណ្ឌិតឈ្មោះ រស់ ឧុទ្ធី** ហៅ ឡូញ ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៤-១៩៩៨ ពីបទរំលោភសេពសន្ថវៈលើស្ត្រីភេទ និងសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៤ ចុះថ្ងៃទី ១៥-៩-១៩៩៨ របស់តុលាការខេត្តស្វាយរៀង ។

**១៨. ទណ្ឌិតឈ្មោះ គូ លន់ណា** ភេទប្រុស អាយុ ៥៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៧-២០០២ ពីបទរំលោភសេពសន្ថវៈលើនារីភេទ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ០២-០១-២០០៣ របស់តុលាការខេត្តស្វាយរៀង ។

**១៩. ទណ្ឌិតឈ្មោះ ញឹម សារុន** ហៅ ទោ ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៣-២០០២ ពីបទសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ០៣-៧-២០០២ របស់តុលាការខេត្តស្វាយរៀង ។

**២០. ទណ្ឌិតឈ្មោះ តេ ភាគ** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៣-២០០២ ពីបទមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩០ ចុះថ្ងៃទី ២១-៨-២០០២ របស់តុលាការខេត្តស្វាយរៀង ។

**២១. ទណ្ឌិតឈ្មោះ គឹម សៅ** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៧-២០០០ ពីបទសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ ចុះថ្ងៃ ២២-១២-២០០០ របស់តុលាការខេត្តស្វាយរៀង ។

**២២. ទណ្ឌិតឈ្មោះ អ៊ុំ សខ** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៧-១៩៩៦ ពីបទរួបរួមគ្នាសម្លាប់មនុស្ស ដោយគិតទុកជាមុនមានអាវុធ និងរួបរួមគ្នាប្លន់យកទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៨ ចុះថ្ងៃទី ២៧-១២-១៩៩៦ របស់តុលាការខេត្តស្វាយរៀង ។

**២៣. ទណ្ឌិតឈ្មោះ ខម្លាប់ មិល** ភេទប្រុស អាយុ ៥២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១១-២០០០ ពីបទភេរវកម្ម និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១១៩ "ង" ចុះថ្ងៃទី ២៨-១២-២០០៥ របស់សាលាឧទ្ធរណ៍ ។

**២៤. ទណ្ឌិតឈ្មោះ សេង ណារិន** ភេទប្រុស អាយុ ៥២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១១-២០០០ ពីបទភេរវកម្ម និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១១៩ "ង" ចុះថ្ងៃទី ២៨-១២-២០០៥ របស់សាលាឧទ្ធរណ៍ ។

**២៥. ទណ្ឌិតឈ្មោះ ម៉ុន ចាន់តូ** ភេទប្រុស អាយុ ៤៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១១-២០០០ ពីបទភេរវកម្ម និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១១៩ "ង" ចុះថ្ងៃទី ២៨-១២-២០០៥ របស់សាលាឧទ្ធរណ៍ ។

**២៦. ទណ្ឌិតឈ្មោះ ហែម ម៉ុនធឿន** ហៅ ហែម អេម ភេទប្រុស អាយុ ៤៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-១១-២០០០ ពីបទភេរវកម្ម និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេច

ROYAUME DU CAMBODGE

ផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១១៩ "ង" ចុះថ្ងៃទី ២៨-១២-២០០៥ របស់សាលាឧទ្ធរណ៍ ។

**២៧. ឧណ្ហិតឈ្មោះ ចាន់ ម៉ុនខេន** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១១-២០០០ ពីបទភេរវកម្ម និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤១ "ង" ចុះថ្ងៃទី ២៧-៤-២០០៥ របស់សាលាឧទ្ធរណ៍ ។

**២៨. ឧណ្ហិតឈ្មោះ ឈឿក អ៊ីវ** ហៅ អោក រ៉ា ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-០២-២០០០ ពីបទប្លន់ និង ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០០ ចុះថ្ងៃទី ១៨-៨-២០០០ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**២៩. ឧណ្ហិតឈ្មោះ ខិន សាល្អន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៧-១៩៩៧ ពីបទធ្វើមនុស្សឃាតគិតទុកជាមុន និងកាន់កាប់អាវុធហាមឃាត់ខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៩ ចុះថ្ងៃទី ០៣-១០-១៩៩៧ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣០. ឧណ្ហិតឈ្មោះ នាង ហ្វា** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៣-២០០១ ពីបទរំលោភសេពសន្ថវៈ និងសម្លាប់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ០៣-១០-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

**៣១. ឧណ្ហិតឈ្មោះ ឈុន មាន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៦-១៩៩៥ ពីបទសមាជិកនយោបាយ និងកម្លាំងក្រុមកម្ពុជាប្រជាធិបតេយ្យ និងបទឃាតកម្មគិតទុកជាមុនហើយ ត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៤ ចុះថ្ងៃទី ២៦-៧-១៩៩៥ របស់តុលាការក្រុងព្រះសីហនុ ។

**៣២. ឧណ្ហិតឈ្មោះ ចាង សែន** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៩-២០០២ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១២-៣-២០០៣ របស់តុលាការខេត្តរតនគីរី ។

**៣៣. ឧណ្ហិតឈ្មោះ គីន នីន** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១០-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ៣០-០១-២០០៣ របស់តុលាការខេត្តរតនគីរី ។

**៣៤- ទណ្ឌិតឈ្មោះ សៀម ផាន់** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៦-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ២២-៧-២០០២ របស់តុលាការខេត្តរតនគិរី ។

**៣៥- ទណ្ឌិតឈ្មោះ ខ៉ាន ធឿង** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៩-២០០២ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១២-៣-២០០៣ របស់តុលាការខេត្តរតនគិរី ។

**មាត្រា ២ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ៥៧ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

**១- ទណ្ឌិតឈ្មោះ ស៊ាន អេន** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-១០-២០០០ ពីបទប្លន់ និងប៉ុនប៉ងមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ១២-០២-២០០១ របស់តុលាការខេត្តក្រចេះ ។

**២- ទណ្ឌិតឈ្មោះ ខៀង យ៉ាំងលីប** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៦-១៩៩៧ ពីបទសម្លាប់មនុស្សដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ២៥-១១-១៩៩៧ របស់តុលាការខេត្តកំពត ។

**៣- ទណ្ឌិតឈ្មោះ ឯម វុទ្ធី** ហៅ ភោគ តាក់ ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-១០-២០០៣ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធ នាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៨-៤-២០០៤ របស់តុលាការខេត្តកំពត ។

**៤- ទណ្ឌិតឈ្មោះ យុង ជុន** ភេទប្រុស អាយុ ៧៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១០-២០០៣ ពីបទសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ ចុះថ្ងៃទី ២១-៥-២០០៤ របស់តុលាការខេត្តកំពត ។

**៥- ទណ្ឌិតឈ្មោះ ខ៉ែត ជ្រាយ** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៧-២០០០ ពីបទសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ ចុះថ្ងៃទី ០១-៣-២០០១ របស់តុលាការខេត្តកំពត ។

**៦- ទណ្ឌិតឈ្មោះ សាន់ ពិសិដ្ឋ** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៥-២០០០ ពីបទធ្វើមនុស្សឃាតដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៤ ចុះថ្ងៃទី ១០-១០-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

ROYAUME DU CAMBODGE

**៧.** **ទណ្ឌិតឈ្មោះ ទិន សុជាតិ** ហៅ ភី ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃ ១៤-៧-១៩៩៧ ពីបទប្លន់សម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៣ ចុះថ្ងៃទី ០៩-៩-១៩៩៧ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**៨.** **ទណ្ឌិតឈ្មោះ រ៉ាយ ឈន** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៨-២០០០ ពីបទសម្លាប់មនុស្សដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥ ចុះថ្ងៃទី ១១-១០-២០០០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**៩.** **ទណ្ឌិតឈ្មោះ ម៉ាន ម៉ាត់** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៤-២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៤ ចុះថ្ងៃទី ១២-៩-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១០.** **ទណ្ឌិតឈ្មោះ ជុំ តុន** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៧-២០០២ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២២ ចុះថ្ងៃទី ០៧-១១-២០០២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១១.** **ទណ្ឌិតឈ្មោះ សៅ ចំរើន** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៩-២០០២ ពីបទបាញ់សម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៨ ចុះថ្ងៃទី ០៤-១២-២០០២ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១២.** **ទណ្ឌិតឈ្មោះ សៅ សាអ៊ុន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៨-២០០១ ពីបទប្លន់ និងសម្លាប់មនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥៤ ចុះថ្ងៃទី ២១-១២-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៣.** **ទណ្ឌិតឈ្មោះ អ៊ុំ ឡុន** ភេទប្រុស អាយុ ៤៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៨-២០០២ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ១០-០២-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៤.** **ទណ្ឌិតឈ្មោះ អៀម សាវ៉ាត** ភេទប្រុស អាយុ ៥៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៩-២០០១ ពីបទអំពើមនុស្សឃាតដោយចេតនា និងប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥០ ចុះថ្ងៃទី ១២-១២-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៥.** **ទណ្ឌិតឈ្មោះ ម៉ុល អ៊ីន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-១២-២០០២ ពីបទចាប់រំលោភសេពសន្ថវៈ លើកូនស្រីរបស់ខ្លួន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់

ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ ចុះថ្ងៃទី ០៩-៤-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៦-  ទណ្ឌិតឈ្មោះ អុំ ចុន** ភេទស្រី អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-០២-២០០១ ពីបទប្លន់ និងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ ចុះថ្ងៃទី ២០-៦-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៧-  ទណ្ឌិតឈ្មោះ សែម ស្រស់** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៣-២០០១ ពីបទប្លន់ប្រដាប់អាវុធ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១១៥ ចុះថ្ងៃទី ២៥-៩-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៨-  ទណ្ឌិតឈ្មោះ ឡៀង សុំ** ហៅ បូក ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៣-២០០១ ពីបទប្លន់ប្រដាប់អាវុធ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១១៥ ចុះថ្ងៃទី ២៥-៩-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៩-  ទណ្ឌិតឈ្មោះ ឡុង សុផល** ហៅ ជា ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅ ថ្ងៃទី ១៧-៣-២០០១ ពីបទប្លន់ប្រដាប់អាវុធ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១១៥ ចុះថ្ងៃទី ២៥-៩-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២០-  ទណ្ឌិតឈ្មោះ សឿន ភា** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៣-២០០១ ពីបទប្លន់ប្រដាប់អាវុធ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១១៥ ចុះថ្ងៃទី ២៥-៩-២០០១ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២១-  ទណ្ឌិតឈ្មោះ អ៊ុន តុប** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-០១-២០០៤ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៧ ចុះថ្ងៃទី ២៤-៥-២០០៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២២-  ទណ្ឌិតឈ្មោះ មូល ឈិន** ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-៧-២០០១ ពីបទសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១០-០១-២០០២ របស់តុលាការខេត្តស្វាយរៀង ។

ROYAUME DU CAMBODGE

**២៣. ទណ្ឌិតឈ្មោះ ប៉ែន សាវ៉ាន់** ហៅ តុប ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅ ថ្ងៃទី ២៨-១០-២០០២ ពីបទរំលោភសេពសន្ថវៈលើនារីភេទ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ ចុះថ្ងៃទី ០៦-៦-២០០៣ របស់តុលាការខេត្តស្វាយរៀង ។

**២៤. ទណ្ឌិតឈ្មោះ សេក ហាយ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-០២-២០០៣ ពីបទរំលោភសេពសន្ថវៈលើកុមារី ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៧ ចុះថ្ងៃទី ១២-៧-២០០៣ របស់តុលាការខេត្តស្វាយរៀង ។

**២៥. ទណ្ឌិតឈ្មោះ ឌឹម ឆាយ៉ា** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-០២-២០០០ ពីបទរួបរួមគ្នាប្លន់ និងសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ២៥-១២-១៩៩២ របស់តុលាការខេត្តស្វាយរៀង ។

**២៦. ទណ្ឌិតឈ្មោះ នាគ សុណា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៧-២០០៣ ពីបទរំលោភសេពសន្ថវៈលើកុមារី ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃ០៥-០១-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

**២៧. ទណ្ឌិតឈ្មោះ អ៊ឹម ទ័ន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៨-២០០២ ពីបទរំលោភសេពសន្ថវៈលើស្ត្រីភេទ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ០២-០១-២០០៣ របស់តុលាការខេត្តស្វាយរៀង ។

**២៨. ទណ្ឌិតឈ្មោះ ប្រាជ្ញ ស៊ីន** ភេទស្រី អាយុ ៤៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-០២-២០០១ ពីបទរួមគ្នាពង្រាត់មនុស្សយកទៅលក់ និងយកទៅធ្វើពេស្យាចារ ហើយត្រូវតុលាការសម្រេចផ្តន្ទា ទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៤ ចុះថ្ងៃទី ១៩-៧-២០០១ របស់តុលាការខេត្តស្វាយរៀង ។

**២៩. ទណ្ឌិតឈ្មោះ ផន ប៊ុនណារិទ្ធ** ហៅ សុខ បូ ហៅ សុខ នៅ ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-៩-២០០១ ពីបទអំពើភេរវកម្ម និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ១០-០១-២០០២ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣០. ទណ្ឌិតឈ្មោះ ឆាត ប្រែង** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៩-២០០០ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ ចុះថ្ងៃទី ១៩-៣-២០០១ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣១. ទណ្ឌិតឈ្មោះ ឡុម សោភ** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-៣-២០០០ ពីបទសមគំនិតឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២០ ចុះថ្ងៃទី ០៤-១០-២០០០ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣២. ទណ្ឌិតឈ្មោះ ថ្លាន់ សារ៉េន** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-៣-២០០០ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលក្រមលេខ ១២០ ចុះថ្ងៃទី ០៤-១០-២០០០ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៣. ទណ្ឌិតឈ្មោះ ជុំ ម៉ុញ** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-៣-២០០០ ពីបទអំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥ ចុះថ្ងៃទី ១០-៨-២០០០ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៤. ទណ្ឌិតឈ្មោះ យិន វណ្ណះ** ហៅ ទន់ ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-១០-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី ០១-៤-២០០២ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៥. ទណ្ឌិតឈ្មោះ យឹម ឃ្លី** ហៅ តូ ប្រឹម ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-១០-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី ០១-៤-២០០២ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៦. ទណ្ឌិតឈ្មោះ ណែម សាឌុន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-១០-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៥ ចុះថ្ងៃទី ០១-៤-២០០២ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៧. ទណ្ឌិតឈ្មោះ វ៉ាន់ ឡុញ** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១២-២០០២ ពីបទអំពើភេរវកម្មក្រុមជនប្រដាប់អាវុធ និងការកាន់កាប់អាវុធផលិតគ្រឿងផ្ទុះដោយខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ ចុះថ្ងៃ ទី ១១-៦-២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៨. ទណ្ឌិតឈ្មោះ រី សារ៉េត** ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១២-២០០២ ពីបទអំពើភេរវកម្មក្រុម និងប្រដាប់អាវុធ និងការកាន់កាប់អាវុធផលិតគ្រឿងផ្ទុះខុសច្បាប់

ហើយ ត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ ចុះថ្ងៃទី ១១ -៦-២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៩. ទណ្ឌិតឈ្មោះ ស៊ុន អៀវ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-១០-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៤ ចុះថ្ងៃទី ២៧-៣-២០០២ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤០. ទណ្ឌិតឈ្មោះ លួន នឿន** ភេទស្រី អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-៨-២០០៣ ពីបទអំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥៣ "ឃ" ចុះថ្ងៃទី ២៦-១១-២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤១. ទណ្ឌិតឈ្មោះ ឆ្លៅ ហុក** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-១២-២០០០ ពីបទរំលោភសេពសន្ថវៈ និងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "ខ" ចុះថ្ងៃទី ២០-៣-២០០១ របស់តុលាការ ខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤២. ទណ្ឌិតឈ្មោះ សំ ទួត** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១០-១៩៩៩ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៧ ចុះថ្ងៃទី ២២-៣-២០០០ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤៣. ទណ្ឌិតឈ្មោះ ស៊ឹម សុភឿន** ភេទស្រី អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-០៦-១៩៩៩ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥០ "ដ" ចុះថ្ងៃទី ១៩-៧-២០០១ របស់តុលាការក្រុងភ្នំពេញ ។

**៤៤. ទណ្ឌិតឈ្មោះ ស្រស់ ហ៊ីង** ភេទស្រី អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-១០-២០០០ ពីបទជួញដូរមនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ៤៨ "ដ" ចុះថ្ងៃទី ១៩-៧-២០០១ របស់តុលាការក្រុងភ្នំពេញ ។

**៤៥. ទណ្ឌិតឈ្មោះ អ៊ិត វណ្ណះ** ហៅ និត ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-៥-២០០៣ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៩ ចុះថ្ងៃទី ១៤-៣-២០០៧ របស់តុលាការកំពូល ។

**៤៦. ទណ្ឌិតឈ្មោះ អ៊ិន សុវណ្ណ** ហៅ អ៊ុល សម្បត្តិ ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំ ខ្លួននៅថ្ងៃទី ០៨-៩-១៩៩៩ ពីបទចាប់មនុស្សជំរិតទារប្រាក់ចំនួន ៣លើក ហើយត្រូវតុលាការ

សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៩ "ង" ចុះថ្ងៃទី ០១-៣-២០០៥ របស់សាលាឧទ្ធរណ៍។

៤៧. **ទណ្ឌិតឈ្មោះ ឌិន សំភាស់** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៣-១៩៩៩ ពីបទប្រព្រឹត្តអំពើភេរវកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ២៧ "ដ" ចុះថ្ងៃទី ០៣-១០-២០០០ របស់តុលាការក្រុងភ្នំពេញ។

៤៨. **ទណ្ឌិតឈ្មោះ ថន យូដេង** ហៅ វែង ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃ ទី ១៤-១២-១៩៩៩ ពីបទភេរវកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាសដីកាលេខ ៨៥ "ង" ចុះថ្ងៃទី ២៣-៨-២០០៥ របស់សាលាឧទ្ធរណ៍។

៤៩. **ទណ្ឌិតឈ្មោះ សឹម ម៉ិនថា** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៨-១៩៩៩ ពីបទអំពើមនុស្សឃាតដោយចេតនា និងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាសក្រមលេខ ៥៧ ចុះថ្ងៃទី ១៧-១២-១៩៩៩ របស់តុលាការក្រុងព្រះសីហនុ។

៥០. **ទណ្ឌិតឈ្មោះ ប៊ូ ផល** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-១២-២០០០ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាសក្រមលេខ ១៤ ចុះថ្ងៃទី ១២-៧-២០០១ របស់តុលាការខេត្តរតនគិរី។

៥១. **ទណ្ឌិតឈ្មោះ ឃុន ឆាំង** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៥-២០០២ ពីបទអំពើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាសក្រមលេខ ២៤ ចុះថ្ងៃទី ១២-៦-២០០២ របស់តុលាការខេត្តរតនគិរី។

៥២. **ទណ្ឌិតឈ្មោះ ថា ផល្លា** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១០-២០០១ ពីបទលួងលោមមនុស្សយកទៅធ្វើពេស្យាចារ និងបៀតបៀនកេរ្តិ៍ខ្មាស់ ហើយត្រូវតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាសក្រមលេខ ១៣ ចុះថ្ងៃទី ០៤-៦-២០០២ របស់តុលាការខេត្តរតនគិរី។

៥៣. **ទណ្ឌិតឈ្មោះ ហ៊ឹម ថេត** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១១ -២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាសក្រមលេខ ០១ ចុះថ្ងៃទី ២២-០១-២០០២ របស់តុលាការខេត្តរតនគិរី។

៥៤. **ទណ្ឌិតឈ្មោះ ៖ ចំរើន** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៦-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាសក្រមលេខ ២៨ ចុះថ្ងៃទី ២២-៧-២០០២ របស់តុលាការខេត្តរតនគិរី។

**៥៥. ទណ្ឌិតឈ្មោះ រំដួល ជុំហាច** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី ២៤-៦-២០០៣ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១០-៣-២០០៤ របស់តុលាការខេត្តរតនគិរី ។

**៥៦. ទណ្ឌិតឈ្មោះ ណារ៉ំ ម៉ុល** ហៅ ណែម ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី ១៥-៨-២០០០ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ "ក" ចុះថ្ងៃទី ០៥-១២-២០០០ របស់តុលាការខេត្តកណ្តាល ។

**៥៧. ទណ្ឌិតឈ្មោះ កែវ វិរៈ** ហៅ នី ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួន នៅថ្ងៃទី ១៤-១១-២០០១ ពីបទធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ "ព" ចុះថ្ងៃទី ៣០-០១-២០០២ របស់តុលាការខេត្តកណ្តាល ។

**មាត្រា ៣ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ៧៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

**១. ទណ្ឌិតឈ្មោះ ឌឹម សារ៉ុំ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៩-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ២៨-៤-២០០៥ របស់តុលាការខេត្តក្រចេះ ។

**២. ទណ្ឌិតឈ្មោះ ប៉ែន អាំ** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-១១-២០០៣ ពីបទប្លន់ ( លួចមានគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណាចសាលក្រមលេខ ៨៧ ចុះថ្ងៃទី ១៥-៦-២០០៤ របស់តុលាការខេត្តក្រចេះ ។

**៣. ទណ្ឌិតឈ្មោះ ស៊ឹម ភួ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-១១-២០០៣ ពីបទប្លន់ ( លួចមានគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណាចសាលក្រមលេខ ៨៧ ចុះថ្ងៃទី ១៥-៦-២០០៤ របស់តុលាការខេត្តក្រចេះ ។

**៤. ទណ្ឌិតឈ្មោះ ខឹម ជឿន** ហៅ ឌី គីមសេង ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី ១២-១១-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ និងកាន់កាប់អាវុធខុសច្បាប់ ១ ឆ្នាំ តែទោសខាងក្រោយនេះព្យួរទាំងស្រុង រយៈពេលសាកល្បង ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ០៩-៦-២០០៥ របស់តុលាការខេត្តកំពត ។

**៥. ទណ្ឌិតឈ្មោះ ទឹម សួល** ភេទស្រី អាយុ ៥៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៧-២០០៦ ពីបទប្រមូលផលអនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត និងបង្កើតរោងសន្និធិ លក់ដុំលក់រាយ

ផលអនុផលព្រៃឈើគ្មានលិខិតអនុញ្ញាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ ចុះថ្ងៃទី ១២-៣-២០០៧ របស់តុលាការខេត្តកំពត ។

៦. **ឧណ្ហិតឈ្មោះ ថាន់ គីមជីន** ហៅ គីម ជិន ភេទស្រី អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-៦-២០០៦ ពីបទសញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ក្នុងនោះត្រូវរងទណ្ឌកម្មក្នុងពន្ធនាគារក្នុងរយៈពេល ២ ឆ្នាំ សល់ពីនោះព្យួរទោស និងមានសាកល្បង ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ០២-០១-២០០៧ របស់តុលាការខេត្តកំពត ។

៧. **ឧណ្ហិតឈ្មោះ យស់ ជា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-០១-២០០៥ ពីបទសមគំនិតក្នុងអំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ៨២ ចុះថ្ងៃទី ២៩-៧-២០០៥ របស់តុលាការខេត្តកំពត ។

៨. **ឧណ្ហិតឈ្មោះ យ៉ូង ថេង** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-០១-២០០៥ ពីបទប្លន់ទ្រព្យសម្បត្តិពលរដ្ឋ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៩ ចុះថ្ងៃទី ០១-៧-២០០៥ របស់តុលាការខេត្តកំពត ។

៩. **ឧណ្ហិតឈ្មោះ ទ៉ាត សុនី** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៧-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ៦ ខែ តាម អំណាចសាលក្រមលេខ ១១៨ "ក" ចុះថ្ងៃទី ២៦-១០-២០០១ របស់តុលាការខេត្តបាត់ដំបង ។

១០. **ឧណ្ហិតឈ្មោះ ចាយ ទិន** ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៤-២០០២ ពីបទក្រុមជនប្រដាប់អាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ "ខ" ចុះថ្ងៃទី ០៦-៨-២០០២ របស់តុលាការខេត្តបាត់ដំបង ។

១១. **ឧណ្ហិតឈ្មោះ សំ ចាន់រិទ្ធ** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៤-២០០២ ពីបទក្រុមជនប្រដាប់អាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ "ខ" ចុះថ្ងៃទី ០៦-៨-២០០២ របស់តុលាការខេត្តបាត់ដំបង ។

១២. **ឧណ្ហិតឈ្មោះ សឿន សុិន** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៤-២០០២ ពីបទក្រុមជនប្រដាប់អាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ "ខ" ចុះថ្ងៃទី ០៦-៨-២០០២ របស់តុលាការខេត្តបាត់ដំបង ។

ROYAUME DU CAMBODGE

**១៣- ទណ្ឌិតឈ្មោះ សុន ម៉ៅ** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-០១-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩ "គ" ចុះថ្ងៃទី ២៩-៥-២០០២ របស់តុលាការខេត្តបាត់ដំបង ។

**១៤- ទណ្ឌិតឈ្មោះ កៅ សុខឃី** ហៅ ប៊ុន វៀច ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួន នៅថ្ងៃទី ២២-៤-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាម អំណាចសាលក្រមលេខ ៦៧ "ក" ចុះថ្ងៃទី ១៧-៦-២០០២ របស់តុលាការខេត្តបាត់ដំបង ។

**១៥- ទណ្ឌិតឈ្មោះ អ៊ុំ ខុច** ហៅ សុខ ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួន នៅថ្ងៃទី ៣០-០១-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ "គ" ចុះថ្ងៃទី ០៥-៥-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

**១៦- ទណ្ឌិតឈ្មោះ រ៉េត ខ្មៅ** ហៅ នី ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួន នៅថ្ងៃទី ៣០-០១-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ "គ" ចុះថ្ងៃទី ០៥-៥-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

**១៧- ទណ្ឌិតឈ្មោះ ចន ចាន់ណា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-០២-២០០៤ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ២៧ "គ" ចុះថ្ងៃទី ៣១-៣-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

**១៨- ទណ្ឌិតឈ្មោះ អ៊ុន សុភាព** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៣-២០០៣ ពីបទប្លន់យកម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ ចុះថ្ងៃទី ២៤-៦-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**១៩- ទណ្ឌិតឈ្មោះ អឿន រិទ្ធិ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-០២-២០០៣ ពីបទប្លន់ និងសម្លាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ៦ ខែ តាមអំណាច សាលក្រមលេខ ៤៧ ចុះថ្ងៃទី ០៩-៤-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២០- ទណ្ឌិតឈ្មោះ សែម សំអុន** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៣-២០០៣ ពីបទប្លន់យកទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៦ ចុះថ្ងៃទី ១២-៩-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២១- ទណ្ឌិតឈ្មោះ ប៊ុត តារុន** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៨-២០០៣ ពីបទរំលោភសេពសន្ថវៈលើកុមារីអាយុ ១២ ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស

ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៩ ចុះថ្ងៃទី ២០-១០-២០០៣ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២២. ទណ្ឌិតឈ្មោះ សុខ សែ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-១០-២០០៤ ពីបទប្លន់យកម៉ូតូ១គ្រឿង ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "គ" ចុះថ្ងៃទី ១០-៣-២០០៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២៣. ទណ្ឌិតឈ្មោះ ទេព សុភឿន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-០១-២០០៥ ពីបទប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ "ឃ" ចុះថ្ងៃទី ១៥-៦-២០០៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២៤. ទណ្ឌិតឈ្មោះ ជា ផាប់** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-៣-២០០៥ ពីបទបង្ករបួសស្នាម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ក" ចុះថ្ងៃទី ០៧-៩-២០០៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២៥. ទណ្ឌិតឈ្មោះ ជឿន ភាព** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១២-២០០៤ ពីបទប្លន់ និងចាប់ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "ឃ" ចុះថ្ងៃទី ២៧-៤-២០០៥ របស់តុលាការខេត្តកំពង់ឆ្នាំង ។

**២៦. ទណ្ឌិតឈ្មោះ គិន យ៉ាក** ហៅ ប្រេះ យ៉ាត ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី ២៣-៤-២០០៤ ពីបទប្លន់ និងលាក់ទុកអាវុធជាតិផ្ទុះខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៦ "ឃ" ចុះថ្ងៃទី ២១-៦-២០០៦ របស់សាលាឧទ្ធរណ៍ ។

**២៧. ទណ្ឌិតឈ្មោះ គ្រូច ម៉ៃ** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៤-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៦ "ឃ" ចុះថ្ងៃទី ២១-៦-២០០៦ របស់សាលាឧទ្ធរណ៍ ។

**២៨. ទណ្ឌិតឈ្មោះ សឿ ឃួយ** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៤-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៦ "ឃ" ចុះថ្ងៃទី ២១-៦-២០០៦ របស់សាលាឧទ្ធរណ៍ ។

**២៩. ទណ្ឌិតឈ្មោះ ឌុល សារ៉ាត** ហៅ ម៉ាប់ ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅ ថ្ងៃទី ១៩-៤-២០០៤ ពីបទរួបរួមគ្នាប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេច

ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៥ ចុះថ្ងៃទី ១៨-១០-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

**៣០- ទណ្ឌិតឈ្មោះ ម៉ឿន សុផល** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៥-២០០២ ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២០ ចុះថ្ងៃទី ២៣-១២-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

**៣១- ទណ្ឌិតឈ្មោះ ជឹម សុវណ្ណ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៥-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៦ ចុះថ្ងៃទី ២៦-១០-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

**៣២- ទណ្ឌិតឈ្មោះ ហ៊ិន អ៊ិត** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-១០-២០០៤ ពីបទអំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៩ ចុះថ្ងៃទី ២៤-៨-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

**៣៣- ទណ្ឌិតឈ្មោះ សុខ គឿន** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៩-២០០៣ ពីបទអំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ ចុះថ្ងៃទី ០៩-៣-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

**៣៤- ទណ្ឌិតឈ្មោះ កែវ ស៊ីថា** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-១២-២០០៥ ពីបទលួចទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ២៦-០១-២០០៦ របស់តុលាការខេត្តស្វាយរៀង ។

**៣៥- ទណ្ឌិតឈ្មោះ អន សារ៉ុន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៨-២០០៥ ពីបទបង្ករបួសស្នាមដោយចេតនាលើអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ២៤-៣-២០០៦ របស់តុលាការខេត្តស្វាយរៀង ។

**៣៦- ទណ្ឌិតឈ្មោះ ញ៉ឹក ពុទ្ធា** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-៥-២០០៥ ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធលើអ្នកដទៃ ហើយត្រូវតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៩ ចុះថ្ងៃទី ០៩-១២-២០០៥ របស់តុលាការខេត្តស្វាយរៀង ។

**៣៧-  ទណ្ឌិតឈ្មោះ ឡេ យ៉ាំងតេច** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-៧-២០០៥ ពីបទសញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ "គ" ចុះថ្ងៃទី ១៩-០១-២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៨-  ទណ្ឌិតឈ្មោះ ជុំ សាម៉ុន** ភេទស្រី អាយុ ៥៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-០១-២០០៦ ពីបទទិញលក់គ្រឿងញៀន បណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៩ "ឃ" ចុះថ្ងៃទី ១២-៧-២០០៦ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៣៩-  ទណ្ឌិតឈ្មោះ សុខ នាន** ភេទស្រី អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១២-២០០៤ ពីបទសមគំនិតប្លន់ និងការកាន់អាវុធដែលហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "ឃ" ចុះថ្ងៃទី ១៣-៦-២០០៥ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤០-  ទណ្ឌិតឈ្មោះ សុខ ពៅ** ភេទស្រី អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៧-១០-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧០ "ក" ចុះថ្ងៃទី ២៧-៤-២០០៥ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤១-  ទណ្ឌិតឈ្មោះ សែ សែន** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-៨-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ក" ចុះថ្ងៃទី ១៦-០២-២០០៥ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤២-  ទណ្ឌិតឈ្មោះ សួន សារ៉ាត** ភេទស្រី អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៧-២០០៣ ពីបទបង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ "ក" ចុះថ្ងៃទី ០៩-០១-២០០៤ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤៣-  ទណ្ឌិតឈ្មោះ ប៉ិម ចយ** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៨-២០០១ ពីបទអំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ១១-០១-២០០២ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤៤-  ទណ្ឌិតឈ្មោះ គុច គ្រិច** ភេទស្រី អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-៦-២០០៣ ពីបទបង្ករបួសស្នាមដោយចេតនា បណ្តាលឱ្យស្លាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧៣ ចុះថ្ងៃទី ១៨-១២-២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤៥. ឧណ្ណិតឈ្មោះ ណាំ ស្រីណុច** ភេទស្រី អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-១០-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨២ "ក" ចុះថ្ងៃទី ១៦-៣-២០០៥ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**៤៦. ឧណ្ណិតឈ្មោះ អ៊ុំ ធឿន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-០២-២០០៤ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ "ថ" ចុះថ្ងៃទី ២៨-៦-២០០៤ របស់តុលាការខេត្តកណ្តាល ។

**៤៧. ឧណ្ណិតឈ្មោះ គង់ វ៉ាន់ថា** ហៅ នុត វ៉ាន់ថា ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-៨-២០០៣ ពីបទប្លន់ និងកាន់កាប់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៤១ "ភ" ចុះថ្ងៃទី ០១-១០-២០០៣ របស់តុលាការខេត្តកណ្តាល ។

**៤៨. ឧណ្ណិតឈ្មោះ សន ថុន** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៧-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាម អំណាចសាលដីកាលេខ ១៤៨ "ង" ចុះថ្ងៃទី ២៣-១០-២០០៦ របស់សាលាឧទ្ធរណ៍ ។

**៤៩. ឧណ្ណិតឈ្មោះ ឈួន ឆែ** ភេទប្រុស អាយុ ១៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-០១-២០០៣ ពីបទប៉ុនប៉ងប្លន់ទ្រព្យសម្បត្តិ និងប៉ុនប៉ងមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទា ទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ២២ "ក" ចុះថ្ងៃទី ២៩-៤-២០០៣ របស់តុលាការខេត្តកណ្តាល ។

**៥០. ឧណ្ណិតឈ្មោះ គួន ម៉េង** ភេទប្រុស អាយុ ៥៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-០១-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាច សាលក្រម លេខ ២៣ "ព" ចុះថ្ងៃទី ២៤-៤-២០០៣ របស់តុលាការខេត្តកណ្តាល ។

**៥១. ឧណ្ណិតឈ្មោះ ស ពិសី** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៩-២០០៤ ពីបទប៉ុនប៉ងប្លន់ និងរក្សាអាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៧៩ "ច" ចុះថ្ងៃទី ១៧-៦-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៥២. ឧណ្ណិតឈ្មោះ មុយ ចាន់** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-០២-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ "ព" ចុះថ្ងៃទី ១១-៦-២០០២ របស់តុលាការខេត្តកណ្តាល ។

ROYAUME DU CAMBODGE

.../...

**៥៣. ឧណ្ហិតឈ្មោះ ម៉ែន ពេជ្យ** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-០១ -២០០៥ ពីបទប្លន់ព្រទ្យសម្បត្តិ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ២៦ "ផ" ចុះថ្ងៃទី ០៧-៦-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៥៤. ឧណ្ហិតឈ្មោះ ស៊ីយ តុលា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៥ -២០០៥ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ៣១ "ថ" ចុះថ្ងៃទី ២៣-៩-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៥៥. ឧណ្ហិតឈ្មោះ អ៊ឹម រតនា** ហៅ សុង មុំ ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅ ថ្ងៃទី ០៨-៤-២០០៥ ពីបទប៉ុនប៉ងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ "ន" ចុះថ្ងៃទី ២៣-៩-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៥៦. ឧណ្ហិតឈ្មោះ អ៊ឹម ដារ៉ា** ហៅ សុង យ៉ា ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅ ថ្ងៃទី ០៨-០២-២០០៥ ពីបទប៉ុនប៉ងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ "ន" ចុះថ្ងៃទី ២៣-៩-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៥៧. ឧណ្ហិតឈ្មោះ ជាប ជាច** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៧-២០០៥ ពីបទប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ៥១ "ផ" ចុះថ្ងៃទី ០១-១២-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៥៨. ឧណ្ហិតឈ្មោះ លន់ ជួន** ហៅ ឡុក ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី ១២-៥-២០០៥ ពីបទចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាម អំណាចសាលក្រមលេខ ៦៧ "វ" ចុះថ្ងៃទី ១១-១១-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៥៩. ឧណ្ហិតឈ្មោះ ទង់ ហេង** ហៅ ចក់ ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួន នៅថ្ងៃទី ១២-៥-២០០៥ ពីបទចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៧ "វ" ចុះថ្ងៃទី ១១-១១-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៦០. ឧណ្ហិតឈ្មោះ ច្រាយ សុខហេង** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវចាប់ខ្លួននៅ ថ្ងៃទី ០៨-៤-២០០៥ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ៤០ "វ" ចុះថ្ងៃទី ០៨-៧-២០០៥ របស់តុលាការខេត្តកណ្តាល ។

**៦១. ឧណ្ហិតឈ្មោះ គីម សំអុល** ហៅ វិនដា ហៅ កយ ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវ ចាប់ខ្លួននៅថ្ងៃទី ២៨-៦-២០០៣ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣២ "ដ" ចុះថ្ងៃទី ០៤-៤-២០០៦ របស់សាលាឧទ្ធរណ៍ ។

ROYAUME DU CAMBODGE

**៦២. ទណ្ឌិតឈ្មោះ ពុន ថេងឡៃ** ភេទប្រុស អាយុ ៥៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១០-២០០៦ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ១៩-០១-២០០៧ របស់តុលាការខេត្តស្ទឹងត្រែង ។

**៦៣. ទណ្ឌិតឈ្មោះ លន ហៀង** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៦-២០០៥ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ១៥១ "ឈ" ចុះថ្ងៃទី ០៨-១១-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

**៦៤. ទណ្ឌិតឈ្មោះ ឡេម ស៊ីដេត** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៦-២០០៥ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រម លេខ ១៥១ "ឈ" ចុះថ្ងៃទី ០៨-១១-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

**៦៥. ទណ្ឌិតឈ្មោះ នួន តារាមៀ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-០២-២០០៥ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤៦ "ឃ" ចុះថ្ងៃទី ០៩-១២-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

**៦៦. ទណ្ឌិតឈ្មោះ សុខ ធារ៉ា** ហៅ រ៉ា ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួន នៅថ្ងៃទី ២៧-០២-២០០៦ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១៤១ "ច" ចុះថ្ងៃទី ០៦-១០-២០០៦ របស់តុលាការ ក្រុងភ្នំពេញ ។

**៦៧. ទណ្ឌិតឈ្មោះ សុខ ចាន់ថា** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-១២-២០០៣ ពីបទសញ្ចារកម្ម និងបទសមគំនិតក្នុងអំពើសញ្ចារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៦ "ឃ" ចុះថ្ងៃទី ១១-៩-២០០៦ របស់សាលាឧទ្ធរណ៍ ។

**៦៨. ទណ្ឌិតឈ្មោះ សោម រដ្ឋា** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៨-២០០៥ ពីបទប្លន់ (ឆក់ក្រវិល) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាម អំណាចសាលដីកាលេខ ៣៧ "ច" ចុះថ្ងៃទី ២៥-៤-២០០៦ របស់សាលាឧទ្ធរណ៍ ។

**៦៩. ទណ្ឌិតឈ្មោះ មុយ សុធារ៉ា** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-០១-២០០៦ ពីបទប្លន់ (ឆក់ក្រវិល) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៧ "ច" ចុះថ្ងៃទី ២៥-៤-២០០៦ របស់សាលាឧទ្ធរណ៍ ។

**៧០. ទណ្ឌិតឈ្មោះ ខែក ខេមរា** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-៣-២០០៥ ពីបទប្លន់ (ឆក់ទូរស័ព្ទ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ១០១ "គ" ចុះថ្ងៃទី ១៦-៨-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

ROYAUME DU CAMBODGE

**៧១. ទណ្ឌិតឈ្មោះ សៀង តុលា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-០២-២០០៥ ពីបទប្លន់ ( ឆក់មានគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៤៩ "ច" ចុះថ្ងៃទី ០៣-១១-២០០៦ របស់សាលាឧទ្ធរណ៍ ។

**៧២. ទណ្ឌិតឈ្មោះ ហេង លីមហួរ** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៧-០១-២០០៦ ពីបទមនុស្សឃាតដោយចេតនា និងប៉ុនប៉ងមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤៩ "ឍ" ចុះថ្ងៃទី ១៥-៨-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

**៧៣. ទណ្ឌិតឈ្មោះ ម៉ែន ចាន់ដារ៉ា** ភេទប្រុស អាយុ ៤៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៩-២០០៥ ពីបទចាប់ជំរិតទារប្រាក់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ០៣ "ឈ" ចុះថ្ងៃទី ១៦-០១-២០០៧ របស់សាលាឧទ្ធរណ៍ ។

**៧៤. ទណ្ឌិតឈ្មោះ អ៊ូច តា** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-១២-២០០៤ ពីបទប្លន់ ( ម៉ូតូ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៥ "ង" ចុះថ្ងៃទី ០៩-៦-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

**៧៥. ទណ្ឌិតឈ្មោះ រម៉ាម ធ្វីន** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-២-២០០២ ពីបទធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាសក្រមលេខ ២០ ចុះថ្ងៃទី ៥-៦-២០០២ របស់តុលាការខេត្តរតនគីរី ។

**៧៦. ទណ្ឌិតឈ្មោះ ម៉ែន ឆឿន** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៥-២០០៥ ពីបទប្លន់ និងធ្វើមនុស្សឃាតគិតទុកជាមុន បង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាសក្រមលេខ ២២ ចុះថ្ងៃទី ៣១-៨-២០០៦ របស់តុលាការខេត្តរតនគីរី ។

**មាត្រា ៤ :** ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ២៦ នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

**១. ទណ្ឌិតឈ្មោះ ឆាយ អេន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៨-២០០៣ ពីបទឆបោកទ្រព្យសម្បត្តិអ្នកដទៃហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ ចុះថ្ងៃទី ២៤-៣-២០០៤ របស់តុលាការខេត្តក្រចេះ ។

ROYAUME DU CAMBODGE

២. **ទណ្ឌិតឈ្មោះ មឿន ខ្លី** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៧-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៥-០១-២០០៤ របស់តុលាការខេត្តក្រចេះ ។

៣. **ទណ្ឌិតឈ្មោះ ឡុន ភួន** ហៅ ហេង ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៧-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៥-០១-២០០៤ របស់តុលាការខេត្តក្រចេះ ។

៤. **ទណ្ឌិតឈ្មោះ ដេង សុខលី** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-១១-១៩៩៩ ពីបទប្លន់ ចាប់ជំរិត និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ១១-៤-២០០០ របស់តុលាការខេត្តក្រចេះ ។

៥. **ទណ្ឌិតឈ្មោះ គិន ផន** ហៅ ទិត ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-៦-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ "គ" ចុះថ្ងៃទី ០១-១០-២០០៣ របស់តុលាការខេត្តបាត់ដំបង ។

៦. **ទណ្ឌិតឈ្មោះ អ៊ឹម អ៊ីន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៣-១៩៩៧ ពីបទមនុស្សឃាតគិតទុកជាមុន និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧២ ចុះថ្ងៃទី ១៣-៦-១៩៩៧ របស់តុលាការខេត្តបាត់ដំបង ។

៧. **ទណ្ឌិតឈ្មោះ ទុំ ពិសិដ្ឋ** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៧-៣-២០០២ ពីបទប្លន់ប្រដាប់អាវុធ ផ្សំគំនិត និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩២ ចុះថ្ងៃទី ២៥-៩-២០០២ របសតុលាការខេត្តកំពង់ឆ្នាំង ។

៨. **ទណ្ឌិតឈ្មោះ អ៊ឹម ធា** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៣-២០០៣ ពីបទប្លន់យកម៉ូតូមួយគ្រឿង ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ១២៣ ចុះថ្ងៃទី ២២-៣-២០០៤ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៩. **ទណ្ឌិតឈ្មោះ យឹម ណា** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៧-១៩៩៨ ពីបទប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រ និងសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ២៨-១០-១៩៩៨ របស់តុលាការខេត្តស្វាយរៀង ។

**១០. ទណ្ឌិតឈ្មោះ ប៉ែន សារ៉ុម** ភេទប្រុស អាយុ ៣៣ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-១០-១៩៩៩ ពីបទរួបរួមគ្នាប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៤-០២-២០០០ របស់តុលាការខេត្តស្វាយរៀង ។

**១១. ទណ្ឌិតឈ្មោះ ហ៊ិន នី** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៩-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១២-០១-២០០៤ របស់តុលាការខេត្តស្វាយរៀង ។

**១២. ទណ្ឌិតឈ្មោះ ឃួន ឃឿន** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-៣-២០០៣ ពីបទប្លន់ និងកាន់កាប់អាវុធដែលហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០០ ចុះថ្ងៃទី ២០-៨-២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

**១៣. ទណ្ឌិតឈ្មោះ អ៊ី អឿន** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-០១-១៩៩៨ ពីបទធ្វើមនុស្សឃាតដោយចេតនា និងរួមគ្នាប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "ក" ចុះថ្ងៃទី ២៥-៨-១៩៩៨ របស់តុលាការខេត្តតាកែវ ។

**១៤. ទណ្ឌិតឈ្មោះ អ៊ឹម តី** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៩- ២០០១ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាច សាលក្រមលេខ ០៨ "ខ" ចុះថ្ងៃទី ១២-៣-២០០២ របស់តុលាការខេត្តតាកែវ ។

**១៥. ទណ្ឌិតឈ្មោះ សោម សុភ័ក្រ** ភេទប្រុស អាយុ ៣៣ ឆ្នាំ ជាប់ចោទពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ០៥-៥-១៩៩១ របស់តុលាការក្រុងព្រះសីហនុ ដោយគិតពីថ្ងៃចាប់ខ្លួនលើកទីមួយនៅថ្ងៃទី ១៤-១២-១៩៩៨ រហូតថ្ងៃរត់ចេញពីពន្ធនាគារថ្ងៃទី ១៧-៦-១៩៩៩ និងគិតបន្តពីថ្ងៃចាប់លើកទីពីរថ្ងៃទី ១៧-៧-២០០១ ។

**១៦. ទណ្ឌិតឈ្មោះ ឈឹន សំអន** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-៤-១៩៩៦ ពីបទធ្វើមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០២ ចុះថ្ងៃទី ០៥-៥-១៩៩៩ របស់សាលាឧទ្ធរណ៍ ។

**១៧. ទណ្ឌិតឈ្មោះ សាន់ ម៉ុនថា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៤-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ២៩ "ភ" ចុះថ្ងៃទី ២៦-៨-២០០៣ របស់តុលាការខេត្តកណ្តាល ។

ROYAUME DU CAMBODGE
ROYAL

**១៨. ទណ្ឌិតឈ្មោះ ម៉ៅសុខ ថាវរិទ្ធ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-០២-២០០៣ ពីបទបង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ "ព" ចុះថ្ងៃទី ២២-៨-២០០៣ របស់តុលាការខេត្តកណ្តាល ។

**១៩. ទណ្ឌិតឈ្មោះ ឈួន កែវ** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៥-១៩៩៦ ពីបទសម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ "វ" ចុះថ្ងៃទី ២៦-៩-១៩៩៦ របស់តុលាការខេត្តកណ្តាល ។

**២០. ទណ្ឌិតឈ្មោះ សឿង ម៉ុនស៊ុង** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-០២-២០០៦ ពីបទដឹកជញ្ជូនគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ២៥-៨-២០០៦ របស់តុលាការខេត្តស្ទឹងត្រែង ។

**២១. ទណ្ឌិតឈ្មោះ ឈុន យូថា** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-០២-២០០៦ ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៥ "ប" ចុះថ្ងៃទី ២៣-១១-២០០៦ របស់តុលាការក្រុងភ្នំពេញ ។

**២២. ទណ្ឌិតឈ្មោះ អ៊ាត អយ** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-៨-១៩៨៨ ពីបទសម្លាប់មនុស្សដោយចេតនា ដោយពួនស្ទាក់ និងបណ្តាលឱ្យមានរបួសស្លាកស្នាមដោយមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសប្រហារជីវិត តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី ១៧-១១-១៩៨៨ របស់តុលាការក្រុងភ្នំពេញ ។

**២៣. ទណ្ឌិតឈ្មោះ សឿ រ៉ាវុធ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៥-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧១ "ខ" ចុះថ្ងៃទី ២៦-៧-២០០៦ របស់សាលាឧទ្ធរណ៍ ។

**២៤. ទណ្ឌិតឈ្មោះ យន់ សុវណ្ណ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៥-២០០២ ពីបទប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧១ "ខ" ចុះថ្ងៃទី ២៦-៧-២០០៦ របស់សាលាឧទ្ធរណ៍ ។

**២៥. ទណ្ឌិតឈ្មោះ ហ៊ិន សុផាន់ណា** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-១-២០០៤ ពីបទប្លន់ប្រដាប់អាវុធ សមគំនិតប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលដីកាលេខ ២៤ "ជ " ចុះថ្ងៃទី ១៦-៣-២០០៦ របស់សាលាឧទ្ធរណ៍ ។

**២៦. ទណ្ឌិតឈ្មោះ ឆាយ ធារិទ្ធ** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវអនុវត្តទោសចាប់ពីថ្ងៃទី ០៣-៣-២០០៥ ពីបទចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមសាល ក្រមលេខ ៣២ ចុះថ្ងៃទី ១៧-១១-២០០៦ របស់តុលាការខេត្តរតនគិរី ។

មាត្រា ៥ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកត.០១០៨.០៤៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨*

លេខ : ៦៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០០៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ឋិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៨/០៤៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

លោក លីម ហ្វ៊ីរនីតា

ជា

## ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០១.០៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨

លេខ : ៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៨/០៤៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

លោក ណាង សុធី

ជា

## ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៩០១.០៤៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨*

លេខ ៦៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៨/០៤៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានៈឯកឧត្តម **ខៀវ សេន** ជំនួយការឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៩០១.០៥២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨*

លេខៈ ៦០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

នស/រកត/០១០៨/០៥០

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ

១-លោកឧត្តមសេនីយ៍ ខួច សម្បត្តិ
២-លោកឧកញ៉ា ឌី ម៉ូ
៣-លោកឧកញ៉ា លឹម ហ៊ុយឡេង
២-លោក លីន គីនម៉ូ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៩០១.០៥៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៨

លេខ : ៥១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
យ៉ង់ ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៨/០៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម គឹម សុខុន ពីទីប្រឹក្សា ឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី។

**មាត្រា ២:** ត្រូវបានតែងតាំង ឯកឧត្តម ខុន ស៊ា ជាទីប្រឹក្សាឯកឧត្តម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី ឋានៈស្មើ រដ្ឋលេខាធិការ ជំនួសឯកឧត្តម គឹម សុខុន ដែលត្រូវបានបញ្ចប់មុខតំណែង។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៥:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤៧.០៤០១.០៥៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨*

លេខ : ៦៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨
**អគ្គលេខាធិការគណៈរដ្ឋាភិបាល**

**ស៊ុន ជិនភេន**

# ព្រះរាជក្រឹត្យ

នស/រកត/០១០៨/០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តមឧកញ៉ា **ចក់ ឡេង**

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

៣៤ល.០៨០១.០៥៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨

លេខ : ៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ចិនកេង

# ព្រះរាជក្រឹត្យ

នស/រកត/០១០៨/០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

**គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា** ចំពោះ

១-ក្រុមហ៊ុន M & V International Manufacturing Ltd .

២-ក្រុមហ៊ុន Tack Fat Garments Cambodia Ltd .

៣-ក្រុមហ៊ុន Terratex Knitting & Garment International Factory Ltd .

៤-ក្រុមហ៊ុន The GAP Inc .

៥-ក្រុមហ៊ុន H & M Hennes & Mauritz GBC AB .

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤ល.០៥០១.០៥៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៨*

លេខ : ៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០០៨
**អគ្គលេខាធិការអង្គរាជរដ្ឋាភិបាល**

**ឃុន ចិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...០៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ និងការប្រគល់សិទ្ធិកាន់កាប់ដី ស្ថិតនៅភូមិពូធឿង សង្កាត់បិតត្រាង និង ភូមិស្នាប់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ .-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ២០១៧ហិកតា១៤ (ពីរពាន់ដប់ប្រាំពីរហិកតា និងដប់បួន) ស្ថិតនៅ ភូមិពូធឿង សង្កាត់បិតត្រាង និង ភូមិស្ទាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាត់ចេញពីតំបន់គំរបព្រៃឈើឆ្នាំ២០០២ ដូចមានក្នុងផែនទីជាឧបសម្ព័ននៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ២ .-**

ត្រូវបានផ្ទេរនិងប្រគល់សិទ្ធិកាន់កាប់ផ្ទៃដីទំហំ ២០១៧ហិកតា១៤ (ពីរពាន់ដប់ប្រាំពីរហិកតា និងដប់បួន) ស្ថិតនៅភូមិពូធឿង សង្កាត់បិតត្រាង និងភូមិស្ទាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជូនក្រុមហ៊ុន សីហនុវីល ស្ពេសល អ៊ីខនណើមី ហ្សូន ដើម្បីធ្វើការអភិវឌ្ឍន៍ជាតំបន់សេដ្ឋកិច្ចពិសេស ។

**មាត្រា ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលក្រុងព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន សីហនុវីល ស្ពេសល អ៊ីខនណើមី ហ្សូនត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ២០០៨**

**ផែនទី ទីតាំងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ**




**សញ្ញាសំគាល់**

- ចំណុចគោល
- ព្រំប្រទល់តំបន់សេដ្ឋកិច្ចពិសេស
- ក. វាលស្រែ ខ. វាលស្រែលិចទឹក
- ក. ចំការ ខ. ដំណាំក្នុងភូមិ
- ចំការដំណាំ
- ចំការឈើហូបផ្លែ
- កសិកម្មពនេចរ
- ដើមឈ្មោតដុះរាត់រាយ
- ក. ព្រៃស្រោងរបស់ព្រៃធំ ខ. ព្រៃស្តើង
- ក. ព្រៃគុម្ពោត ខ. វាលស្មៅ
- វាលស្មៅលិចទឹក
- ព្រៃគុម្ពោតលិចទឹក
- ព្រៃលិចទឹក
- ក. ជំរាបបឹង ខ. ព្រៃកោងកាង

មាត្រដ្ឋាន ១ : ៤០ ០០០

**ប្រព័ន្ធកូអរដោនេ** (COORDINATE SYSTEM)

| | | |
|---|---|---|
| ចំណោលភាគប្រើប្រាស់ (Projection) | : | យូធីអឹម (UTM) |
| តំបន់ (Zone) | : | ៤៨ |
| គំរូផ្តេកមូលដ្ឋាន (Horizontal datum) | : | ដាប់ប៊ែលយូ ជី អេស ៨៤ (WGS 84) |
| ប្រព័ន្ធផែនដី (Spheroid) | : | អេវើរេស (Everest) |
| បណ្តាញក្រឡាយូធីអឹម (UTM grid) | : | ២ គីឡូម៉ែត្រ (2 Kilometers) |

**តារាង និយាមកាចំណុចកោណព្រំប្រទល់តំបន់សេដ្ឋកិច្ចពិសេស**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| តំបន់ A | | | 32 | 354871.83 | 1173756.24 |
| 1 | 351824.34 | 1174444.58 | 33 | 354632.19 | 1173239.39 |
| 2 | 351554.02 | 1173434.07 | 34 | 354377.53 | 1173512.86 |
| 3 | 351236.46 | 1173004.32 | 35 | 354471.01 | 1173745.55 |
| 4 | 351229.74 | 1172572.96 | 36 | 354576.04 | 1173718.94 |
| 5 | 350283.71 | 1172498.71 | 37 | 354643.37 | 1173916.66 |
| 6 | 349644.34 | 1172678.68 | តំបន់ D | | |
| 7 | 349803.35 | 1172364.17 | 38 | 351318.95 | 1175863.23 |
| 8 | 349380.40 | 1172343.05 | 39 | 352621.00 | 1175618.00 |
| 9 | 349178.31 | 1172561.63 | 40 | 354048.32 | 1175509.77 |
| 10 | 349347.71 | 1172725.80 | 41 | 353814.00 | 1176504.00 |
| 11 | 349229.83 | 1172829.20 | 42 | 355036.00 | 1176561.00 |
| 12 | 349072.12 | 1172663.63 | 43 | 354955.86 | 1175146.54 |
| 13 | 348870.17 | 1172764.59 | 44 | 354957.00 | 1173787.00 |
| 14 | 349354.85 | 1173465.86 | តំបន់ E | | |
| 15 | 350058.46 | 1173535.58 | 45 | 349494.16 | 1179340.53 |
| 16 | 349993.56 | 1174439.72 | 46 | 350021.82 | 1180132.47 |
| 17 | 350457.14 | 1175840.64 | 47 | 349743.74 | 1180271.10 |
| 18 | 349871.00 | 1176098.00 | 48 | 349743.10 | 1180548.59 |
| 19 | 350078.00 | 1177090.00 | 49 | 349763.23 | 1180703.91 |
| 20 | 348639.80 | 1177286.74 | 50 | 349943.48 | 1180713.43 |
| 21 | 349348.90 | 1179436.16 | 51 | 349958.78 | 1180928.46 |
| តំបន់ B | | | 52 | 350046.63 | 1181010.10 |
| 22 | 352979.39 | 1173823.29 | 53 | 350840.64 | 1180473.78 |
| 23 | 352992.85 | 1173350.71 | 54 | 350622.12 | 1179418.68 |
| 24 | 352721.87 | 1173367.15 | 55 | 350384.30 | 1178443.59 |
| 25 | 352710.22 | 1173421.23 | តំបន់ F | | |
| 26 | 352467.65 | 1173500.96 | 56 | 348402.89 | 1176102.53 |
| 27 | 352466.90 | 1173668.46 | 57 | 347997.20 | 1176086.43 |
| 28 | 352090.71 | 1173605.11 | 58 | 347805.58 | 1176088.63 |
| 29 | 352091.73 | 1173753.96 | 59 | 347624.25 | 1176179.91 |
| 30 | 351830.00 | 1173989.00 | 60 | 347503.74 | 1176514.94 |
| 31 | 351912.69 | 1174363.08 | 61 | 347668.54 | 1176828.29 |
| តំបន់ C | | | 62 | 348045.96 | 1177022.15 |
| 32 | 354871.83 | 1173756.24 | 63 | 348202.27 | 1176718.70 |
| 33 | 354632.19 | 1173239.39 | 64 | 348483.24 | 1176676.19 |

| ល.រ | តំបន់ | ផ្ទៃដី (ហិកតា) |
|---|---|---|
| ១ | A | ១១១៣.៩៦ |
| ២ | B | ៩៦.៧៨ |
| ៣ | C | ១៦.២៧ |
| ៤ | D | ៥៦៥.៩៣ |
| ៥ | E | ១៩៩.២៧ |
| ៦ | F | ៦៨.៩៤ |
| ផ្ទៃដីសរុប | | ២០១៧.១៤ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសំរួលប្តូរឈ្មោះនាយកដ្ឋានពតិមានទូទៅ ទៅជា នាយកដ្ឋានសន្តិសុខផ្ទៃក្នុង នៃក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ បក ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៧ ស្តីពីការកែសំរួលតួនាទី ភារកិច្ច របស់នាយកដ្ឋានពតិមានទូទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានកែសំរួលប្តូរឈ្មោះនាយកដ្ឋានពតិមានទូទៅ ទៅជានាយកដ្ឋានសន្តិសុខផ្ទៃក្នុង ដែលស្ថិតនៅចំណុះនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានសន្តិសុខផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ នៃរាជរដ្ឋាភិបាល
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚✱៛៛៛

រាជរដ្ឋាភិបាលកម្ពុជា

លេខ ០៩ អនុក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានចំណុះលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម

៚៚៚✱៛៛៛

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧ ០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧ ០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ៨០ សសរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៤-លេខ ២៥ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៥-លេខ៨០ សសរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០០៥-លេខ ២៨ សសរ ចុះថ្ងៃ ទី ១៣ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើត ការបន្ថែមសមាសភាព និងកែសម្រួលសមាសភាពគណៈកម្មាធិការជាតិ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ បញ្ហាការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់អំពើភេរវកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

មាត្រា ១ :-

អនុក្រឹត្យនេះកំណត់ពីរចនាសម្ព័ន្ធ និងការបង្កើតនាយកដ្ឋាននានាចំណុះឱ្យលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំបញ្ហាការប្រយុទ្ធ ប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម (ហៅខ្លីថាគណៈកម្មាធិការ

ជាតិប្រឆាំងភេរវកម្ម-អក្សរកាត់ គជបភ) ដើម្បីឱ្យលេខាធិការដ្ឋាន គជបភ អាចបំពេញបាននូវភារកិច្ចរបស់ខ្លួនផង ហើយលើមូលដ្ឋាននេះ ជួយដល់ប្រធាន គជបភ បំពេញនូវភារកិច្ចរបស់ គជបភ ផង ដែលរួមមាន ៖

**ភារកិច្ចរបស់ គជបភ ៖**

១-ពិនិត្យ និងវិភាគព័ត៌មានដែលទទួលបានពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការសន្និដ្ឋានវាយតំលៃ រួចដាក់ចេញនូវវិធានការជាក់ស្តែង ។

២-ដឹកនាំបញ្ជាដល់កងកម្លាំងមានសមត្ថកិច្ចគ្រប់ប្រភេទ ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងអំពើភេរវកម្ម ដែលបានកើតមានឡើងហើយ ។

៣-ពិនិត្យពិចារណា ដើម្បីលើកវិធានការទប់ស្កាត់គ្រប់សកម្មភាពភេរវកម្មឱ្យបានទាន់ពេលវេលា ។

៤-ទំនាក់ទំនង សហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃបណ្តាប្រទេសជាមិត្ត និងអង្គការអន្តរជាតិនានា នៅក្នុងតំបន់ និងនៅលើពិភពលោក ដើម្បីប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ។

**ភារកិច្ចរបស់លេខាធិការដ្ឋាន គជបភ ៖**

១-កសាង គ្រួតពិនិត្យការអនុវត្តន៍ និងធ្វើជាសេនាធិការជូន គជបភ ក្នុងការកែសម្រួលយុទ្ធសាស្ត្រជាតិ នៃការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ។

២-ប្រមូល និងសរុបព័ត៌មានចារកម្មពីគ្រប់ស្ថាប័ន និងព័ត៌មានផ្សេងៗទៀត វិភាគ វាយតំលៃ និងស្នើសុំវិធានការ ។

៣-ស្រាវជ្រាវអំពើភេរវកម្ម (ប្រមូល និងចងក្រងឯកសារ និងព័ត៌មាន រាប់ទាំងឯកសារព័ត៌មានដែលបានពីបរទេសផង-សួរចំលើយឈ្លេចយកព័ត៌មានបន្ថែមទៀតពីមុខសញ្ញាក្នុង និងក្រៅប្រទេស) ។

៤-សិក្សារកចំណុចខ្សោយដែលត្រូវបំពេញ និងអ្វីដែលភេរវករអាចធ្វើទៅបានដែលយើងនឹកគិតមិនដល់ ។

៥- សិក្សាពង្រឹងសមត្ថភាព និងជំនាញក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ។

៦-បណ្តុះបណ្តាលជំនាញនានា បំពាក់បំប៉នវិធីសាស្ត្រការប្រយុទ្ធប្រឆាំងនិងទប់ស្កាត់អំពើភេរវកម្ម។

៧-រៀបចំផែនការការពារគោលដៅ (ការពារហេដ្ឋារចនាសម្ព័ន្ធ)-ផែនការសង្គ្រោះ-ផែនការឃោសនាអប់រំមហាជន-ដឹកនាំការផ្សព្វផ្សាយព័ត៌មាន ពេលមានគ្រោះអាសន្ន និងវិបត្តិកើតឡើង ។

៨- សិក្សា និងរៀបចំកម្លាំងពិសេស កម្លាំងអន្តរាគមន៍ កម្លាំងសង្គ្រោះបន្ទាន់ និងបណ្តាញការងារជំនាញគាំទ្រផ្សេងទៀត ដូចជាបណ្តាញការងារសង្គ្រោះបឋម ការងារកោសល្យវិច័យ ការងារវិភាគគ្រឿងផ្ទុះ - ជាតិគីមីជីវសាស្ត្រ - សព្វាវុធនុយក្លេអ៊ែរ - និងមូលដ្ឋានបច្ចេកទេសសម្ភារ៉ា និងចំហរនានា ។

៩-កសាងធនាគារព័ត៌មានដោយប្រព័ន្ធកុំព្យូទ័រ និងកសាងមូលដ្ឋានបច្ចេកវិទ្យាកុំព្យូទ័រ តភ្ជាប់ព័ត៌មានឯកសារពីច្រកទ្វារអន្តរជាតិ ស្ថាប័ននានាមកលេខាធិការដ្ឋាននៃ គជបភ ។

១០-សិក្សាទិដ្ឋភាពច្បាប់-អនុសញ្ញានិងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធអំពើភេរវកម្ម និងធ្វើរបាយការណ៍អនុវត្តអនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិទាំងនោះជូនអង្គការសហប្រជាជាតិតាមការកំណត់។

១១-និងបំពេញការងារមួយចំនួនទៀតដែលប្រធាននៃ គជបភ ប្រគល់ឱ្យ ។

## ជំពូក ២

**មាត្រា ២ :-**

ប្រធាន គជបភ ដឹកនាំផ្ទាល់លើ គជបភ និងលើលេខាធិការដ្ឋាន គជបភ - តែងតាំង និងបែងចែក

ភារកិច្ចឱ្យប្រធាន អនុប្រធានទីមួយ-អនុប្រធាន-អនុប្រធានប្រចាំការ-សមាជិក-សមាជិកប្រចាំការលេខាធិការដ្ឋាន គជបភ ។

ប្រធាន គជបភ ចេញសេចក្តីប្រកាសបង្កើតការិយាល័យចំណុះនាយកដ្ឋាននានាក្នុងលេខាធិការដ្ឋាន គជបភ និងសេចក្តីប្រកាសតែងតាំងមន្ត្រីលេខាធិការដ្ឋាន គជបភ ចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានចុះមក ។

ប្រធាន គជបភ ធ្វើសំណើសុំនាយករដ្ឋមន្ត្រីតែងតាំងនិងស្នើតែងតាំងមន្ត្រីក្នុងលេខាធិការដ្ឋានចាប់ពីថ្នាក់ប្រធាននាយកដ្ឋានឡើងទៅ ។

**មាត្រា ៣ :-**

**មន្ត្រីបុគ្គលិកបំពេញការងារនៅក្នុងលេខាធិការដ្ឋាន គជបភ មាន៖**

- **មន្ត្រីបុគ្គលិកពេញម៉ោង:** ទទួលប្រាក់បៀវត្សរ៍ និងមានក្របខ័ណ្ឌក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ។ មន្ត្រីបុគ្គលិកពេញម៉ោងត្រូវជ្រើសរើសអ្នកដែលមានក្របខ័ណ្ឌស្រាប់ពីស្ថាប័នស៊ីវិល-នគរបាល-យោធា-មុខងារសាធារណៈ ឱ្យអស់លទ្ធភាពមុននឹងស្នើសុំជ្រើសរើសអ្នកថ្មី ។
- **មន្ត្រីបុគ្គលិកកាតព្វកិច្ចពីមួយឆ្នាំដល់បីឆ្នាំ** ដែលស្ថាប័នពាក់ព័ន្ធនានាត្រូវបញ្ជូនឱ្យមកធ្វើការពេញម៉ោង និងពាក់កណ្តាលពេល នៅលេខាធិការដ្ឋាន គជបភ ។ មន្ត្រីបុគ្គលិកកាតព្វកិច្ចពីមួយឆ្នាំដល់បីឆ្នាំ ទទួលប្រាក់បៀវត្សរ៍ និងមានក្របខ័ណ្ឌនៅតាមអង្គភាពដើម ។
- ក្នុងករណីចាំបាច់លេខាធិការដ្ឋាន គជបភ អាចជ្រើសរើសមន្ត្រីបុគ្គលិកជំនាញជាប់កិច្ចសន្យាបាន ។

**មាត្រា ៤ :-**

ទីស្តីការគណៈរដ្ឋមន្ត្រី - ក្រសួងមហាផ្ទៃ - ក្រសួងការពារជាតិ និងស្ថាប័នពាក់ព័ន្ធនានា ត្រូវផ្តល់ទីតាំង ធនធានមនុស្ស និងមធ្យោបាយសំរាប់លេខាធិការដ្ឋាន គជបភ បំពេញភារកិច្ច។

លេខាធិការដ្ឋាន គជបភ មានថវិកាដោយឡែករបស់ខ្លួនចំណុះនៅទីស្តីការគណៈរដ្ឋមន្ត្រី ។លេខាធិការដ្ឋាន គជបភ ធ្វើគំរោងចំណាយថវិកាប្រចាំឆ្នាំជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្នុងករណីពិសេសលេខាធិការដ្ឋាន គជបភ ស្នើសុំនាយករដ្ឋមន្ត្រី នូវថវិកាបន្ថែមតាមការចាំបាច់ ។

លេខាធិការដ្ឋាន គជបភ បែងចែកថវិកាទៅតាមនាយកដ្ឋាន និងផ្នែកនានាក្នុងលេខាធិការដ្ឋាន គជបភ និងតាមដានរំលឹកការអនុវត្តន៍ថវិកាដល់គ្រប់ផ្នែកនានា ។ ដោយឡែកទាល់តែមានការអនុញ្ញាតពីប្រធាន គជបភ និងពីនាយករដ្ឋមន្ត្រី ទើបនាយកដ្ឋានចារកម្ម និងស៊ើបអង្កេត អាចលាតត្រដាងឯកសារចំណាយលំអិតនៃបេសកកម្មរបស់ខ្លួន ។

**មាត្រា ៥ :-**

អនុប្រធានប្រចាំការ-សមាជិកប្រចាំការនៃលេខាធិការដ្ឋាន គជបភ គឺជាអ្នកបំពេញភារកិច្ចពេញម៉ោង ឬក៏ជាអ្នកធ្វើការភាគច្រើននៅក្នុងលេខាធិការដ្ឋាន គជបភ ឬជាអ្នកដែលកិច្ចការរបស់ខ្លួនទទួលបន្ទុកនោះមានការទាក់ទង និងគាំទ្រច្រើនដល់លេខាធិការដ្ឋាន គជបភ ។

មានតែសមាសភាពប្រចាំការ និងសមាសភាពមួយចំនួនទៀតដែលមានការងារគ្រង់ជាមួយលេខាធិការដ្ឋាន គជបភ ដែលប្រធាន គជបភ អាចស្នើសុំឋានៈពីអគ្គនាយករងឡើងទៅបាន ។

អនុប្រធានប្រចាំការ សមាជិកប្រចាំការ-ប្រធាននាយកដ្ឋានចំណុះលេខាធិការដ្ឋាន គជបភ រាយការណ៍ជូនប្រធាន គជបភ និងប្រធានលេខាធិការដ្ឋាន គជបភ ជាទៀងទាត់នូវការងាររបស់ខ្លួន លើក

លែងតែការងារពាក់ព័ន្ធចារកម្ម និងព័ត៌មានសម្ងាត់ផ្សេងៗទៀត គ្រប់របាយការណ៍ការងារទាំងអស់ខាងលើនេះត្រូវតែបញ្ជូនទៅថ្នាក់លើនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងរក្សាទុកជាឯកសារនៅក្នុងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុរបស់លេខាធិការដ្ឋាន គជបភ ។

មាត្រា ៦ :~

**លេខាធិការដ្ឋាន គជបភ មានរចនាសម្ព័ន្ធជានាយកដ្ឋាន រួចមាន ៖**

១-នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ (Department of Administration&Finance – DAF)

២-នាយកដ្ឋានព័ត៌មានបច្ចេកវិទ្យា (Department of Information Technology – DIT)

៣-នាយកដ្ឋានចារកម្ម និងស៊ើបអង្កេត (Department of Intelligence & Investigation – DII)

៤-នាយកដ្ឋានការពារហេដ្ឋារចនាសម្ព័ន្ធ (Department of Infrastructure Protection –DIP)

៥-នាយកដ្ឋានពិសេស (Special Department – SD)

នាយកដ្ឋាននីមួយៗដឹកនាំ និងគ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

នាយកដ្ឋានពិសេសមានរចនាសម្ព័ន្ធដោយឡែករបស់ខ្លួន ។

គជបភ លេខាធិការដ្ឋាន គជបភ នាយកដ្ឋានចារកម្ម និងស៊ើបអង្កេត និងនាយកដ្ឋានពិសេស/បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម មានត្រាប្រើប្រាស់ដោយឡែករបស់ខ្លួន ។

## ជំពូក ៣

## នាយកដ្ឋាន

មាត្រា ៧:~

**នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ៖**

១- សំរបសំរួលដល់សកម្មភាព របស់គណៈកម្មាធិការជាតិ និងរបស់លេខាធិការដ្ឋាន គជបភ។

២- គ្រប់គ្រង និងរក្សាឯកសាររដ្ឋបាលផ្សេងៗរបស់លេខាធិការដ្ឋាន គជបភ ។

៣- បូកសរុប របាយការណ៍ សភាពការណ៍ និងការងាររបស់លេខាធិការដ្ឋាន គជបភ ។

៤- គ្រប់គ្រងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងមន្ត្រីបុគ្គលិករបស់លេខាធិការដ្ឋាន គជបភ ។

៥- លើកនិងអនុវត្តគំរោងថវិកាប្រចាំឆ្នាំរបស់លេខាធិការដ្ឋាន រំលឹកការអនុវត្តន៍ថវិកា-គ្រប់គ្រងគណនី -ប្រមូលផ្តុំចំណូល និងចំណាយរបស់លេខាធិការដ្ឋាន-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ ធ្វើបញ្ជីសារពើភ័ណ្ឌ បែងចែកសំភារៈ និងភ័ស្តុភារទៅតាមគំរោងចំណាយ រៀបចំ និងបើកប្រាក់បៀវត្សរ៍ ប្រាក់ឧបត្ថម្ភដល់មន្ត្រីបុគ្គលិក និងកម្លាំងពិសេសនានា ។

៦- សំរបសំរួលផែនការដែលនាយកដ្ឋាននានាចងក្រងមក ហើយកសាងឱ្យទៅជាផែនការសរុបរបស់លេខាធិការដ្ឋាន គជបភ សំរាប់ការប្រឆាំងភេរវកម្ម – ការពង្រឹងសមត្ថភាពជាតិ – ការប្រមូលព័ត៌មាន និងការសរុបព័ត៌មាន – ការបណ្តុះបណ្តាល – ការកសាងកម្លាំងពិសេសនានា – កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ – របាយការណ៍សំរាប់អង្គការសហប្រជាជាតិ... ។

៧- គ្រប់គ្រងនិងធានាសន្តិសុខសុវត្ថិភាព អនាម័យកន្លែងធ្វើការរបស់លេខាធិការដ្ឋាន ។

មាត្រា ៨:~

**នាយកដ្ឋានព័ត៌មានបច្ចេកវិទ្យាមានភារកិច្ចដូចតទៅ៖**

១- សិក្សា និងផ្តល់យោបល់ពីព័ត៌មានបច្ចេកវិទ្យា និងឧបករណ៍ ទាំងផ្នែករឹង ផ្នែកទន់ ផ្នែកការី ក្នុងបំណងត្រួតពិនិត្យ បង្ការទុកជាមុន រកឃើញទាន់ពេលវេលានូវព័ត៌មានដែលមានតំរូវការដល់ការប្រយុទ្ធប្រឆាំងទៅនឹងអំពើភេរវកម្ម ។

២-សិក្សាច្នៃប្រឌិត និងតម្លើងឧបករណ៍ព័ត៌មានបច្ចេកវិទ្យា និងអភិវឌ្ឍកម្មវិធីប្រើប្រាស់ផ្នែក្នុងសំដៅលើកកំពស់សមត្ថភាពវិភាគ - ការរក្សាទុកទិន្នន័យ - ល្បឿនការងារលឿន និងមានប្រសិទ្ធភាពធានាភាពសម្ងាត់ដល់គ្រប់ផ្នែកការងារក្នុង និងក្រៅលេខាធិការដ្ឋាន ។

៣-រៀបចំ និងអភិវឌ្ឍកម្មវិធីធានាភាពសម្ងាត់ដាច់ខាតក្នុងការបញ្ជូនសារ និងព័ត៌មានក្នុង និងក្រៅប្រទេស ។

៤- កសាងផែនការជាតិ ក្នុងការបំពាក់ឧបករណ៍សន្តិសុខ និងបណ្តុះបណ្តាលធនធានមនុស្ស ។

៥- រៀបចំ និងអភិវឌ្ឍកម្មវិធីគ្រប់គ្រងឧបករណ៍ពិសេសនានា ។

៦-កសាងធនាគារព័ត៌មាន-មូលដ្ឋានសំរាប់តភ្ជាប់ប្រព័ន្ធកុំព្យូទ័រដែលរក្សាទុកទិន្នន័យនានា ។

៧- អប់រំផ្សព្វផ្សាយពីគោលនយោបាយ ពីព័ត៌មាន និងពីសភាពការណ៍វិជ្ជមាននានា សំដៅលើកកំពស់កម្លាំងមហាជន ដែលជាផែនសន្តិសុខជាតិឱ្យកាន់តែចូលរួមប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

៨- ឃោសនាអប់រំក្នុង និងក្រៅប្រទេសអំពីការងារ គជបភ ដោយគ្រប់រូបភាព ក្នុងនោះមានទាំងរូបភាពវិបសាយ ។

មាត្រា ៩:-

**នាយកដ្ឋានចារកម្ម និងស៊ើបអង្កេតមានភារកិច្ចដូចតទៅ ៖**

១- នាយកដ្ឋានចារកម្ម និងស៊ើបអង្កេត គឺជាមជ្ឈមណ្ឌលវិភាគ និងព្យាករណ៍មួយរបស់ប្រធាន គជបភ ហេតុនេះត្រូវប្រមូលពិនិត្យ សរុប វិភាគ សន្និដ្ឋាន និងព្យាករណ៍ព័ត៌មានសម្ងាត់ ចំហរ ដែលទទួលបានពីគ្រប់មជ្ឈដ្ឋានដោយចែកប្រភេទព័ត៌មានតាមភូមិសាស្ត្រ និងប្រធានបទនីមួយៗជូនប្រធាន គជបភ ។

២- ប្រមូលព័ត៌មាន និងតាមដានមុខសញ្ញាដោយកម្លាំងរបស់នាយកដ្ឋានផ្ទាល់ - និងដោយកម្លាំងសហប្រតិបត្តិការជាតិ និងអន្តរជាតិ ជាទ្វេ ឬជាពហុភាគី ។

៣- កសាងកម្លាំងផ្តល់ព័ត៌មានសម្ងាត់គ្រប់ប្រភេទ ផ្គត់ផ្គង់ ឧបត្ថម្ភ បណ្តុះបណ្តាល បំពាក់បំប៉នជំនាញដល់កម្លាំងទាំងនោះ ។

៤-ស្រាវជ្រាវព័ត៌មានភេរវកម្ម ដោយប្រមូលឯកសារព័ត៌មានក្នុង និងក្រៅប្រទេស - ព័ត៌មានបានមកពីការឈ្លេចសួរចម្លើយពីមុខសញ្ញាក្នុងនិងក្រៅប្រទេស ។

៥-ធានាអង្គប្រជុំទៀងទាត់សំរាប់ផ្លាស់ប្តូរ - ចែករំលែកព័ត៌មាន និងការវិភាគជាមួយគ្រប់ស្ថាប័នចារកម្មក្នុងប្រទេសទាំងអស់ - កសាងទម្រង់របាយការណ៍ឯកភាពសំរាប់សរុប សង្ខេបនិងវិភាគជូនប្រធាន គជបភ និងថ្នាក់ដឹកនាំផ្សេងៗទៀត ។

៦- ធ្វើការបណ្តុះបណ្តាលឯកភាពនៅក្នុងប្រទេស និងក្រៅប្រទេស អំពីការងារចារកម្មសំរាប់កម្លាំងរបស់លេខាធិការដ្ឋាន គជបភ និងសំរាប់ស្ថាប័នចារកម្មកម្ពុជាផ្សេងទៀត ។

៧- ធ្វើការតាមដានមុខសញ្ញា ។

៨-ធ្វើការស៊ើបអង្កេតលើករណីដែលបានកើតឡើង ។ ផ្តល់ភស្តុតាង និងសាក្សីដែលបានមកពីការស៊ើប

អង្កេតជូនដល់សមត្ថកិច្ចច្បាប់ ។

៩-សំរបសំរួលដល់ស្ថាប័ន និងកងកម្លាំងនានាក្នុងពេលមានគ្រោះភេរវកម្មកើតឡើង ។

១០-មានអ្នកជំនាញសំរាប់ការចរចារពេលមានការចាប់ជំរិត និងបណ្តុះបណ្តាលការចរចារដល់គ្រប់ផ្នែកគ្រប់ថ្នាក់នៃស្ថាប័ននានាដែលពាក់ព័ន្ធដល់ការដោះស្រាយចំណាប់ខ្មាំង ។

១១-សំរបសំរួលសហប្រតិបត្តិការ និងចែករំលែកព័ត៌មានជាមួយស្ថាប័នចារកម្មបរទេស ដែលប្រធាន គជបភ និងនាយករដ្ឋមន្ត្រីផ្តល់ការអនុញ្ញាត ។

១២- គ្រប់គ្រងមូលដ្ឋាន និងឧបករណ៍ពិសេសនានាសំរាប់ការប្រមូលព័ត៌មាន ។

១៣-កំណត់ និងគ្រប់គ្រងបញ្ជីខ្មៅថ្នាក់ជាតិ និងត្រួតពិនិត្យការអនុវត្តន៍បញ្ជីខ្មៅតាមគ្រប់ច្រកទ្វារ និងតាមអង្គភាពរដ្ឋ ឯកជនដែលពាក់ព័ន្ធ ។

១៤- ទំនាក់ទំនងសុំ និងទាមទារព័ត៌មាន ឯកសារ ការបំភ្លឺ ចាំបាច់ពាក់ព័ន្ធដល់មុខសញ្ញា និងកម្មវត្ថុនានានៃប្រតិបត្តិការរបស់ខ្លួន ដោយរក្សាការសម្ងាត់ដល់បុគ្គល អង្គភាពរដ្ឋ – ឯកជន ដែលជាម្ចាស់ និងជាអ្នកផ្តល់ព័ត៌មាន ឯកសារ និងការបំភ្លឺទាំងនោះ ។

១៥-នាយកដ្ឋានទទួលកញ្ចប់ថវិកាពីលេខាធិការដ្ឋាន គជបភ និងធ្វើការទូទាត់ប្លុកសរុបជារួម តាមកំរិតរក្សាឱ្យបានការសម្ងាត់ជូនមកឱ្យលេខាធិការដ្ឋាន គជបភ វិញ ។

១៦-ដើម្បីរក្សាការសម្ងាត់ លិខិតឧទ្ទេសនាមបេសកកម្មនៃកម្លាំងរបស់នាយកដ្ឋានចុះតាមខេត្តក្រុង ស្ថាប័ននានា មិនចាំបាច់មានហត្ថលេខា និងបោះត្រាពីទីកន្លែងបញ្ជាក់ថា មន្ត្រីយើងបានទៅដល់ទីនោះទេ ។

មាត្រា ១០:~

**នាយកដ្ឋានការពារហេដ្ឋារចនាសម្ព័ន្ធមានភារកិច្ចដូចតទៅ ៖**

១-ជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើភេរវកម្ម។ ប្រសិនបើចាំបាច់ផ្តើមគំនិតកែសម្រួលផែនការយុទ្ធសាស្ត្រជាតិជារៀងរាល់ឆ្នាំ ឱ្យសមស្របតាមសភាពការណ៍ថ្មីៗ ។

២-រៀបចំសៀវភៅផែនការការពារទីតាំង និងគោលដៅនីមួយៗសំរាប់កម្លាំងអន្តរាគមន៍គ្រប់ផ្នែក កម្លាំងសង្គ្រោះបន្ទាន់ ជាលក្ខណៈសរុបកម្លាំងសមត្ថកិច្ចទាំងអស់ដែលចូលពាក់ព័ន្ធឱ្យទៅជាផែនការសរុបថ្នាក់ជាតិមួយ ។ លើមូលដ្ឋាននោះ កែតម្រូវតាមសភាពការណ៍ថ្មីជារៀងរាល់ឆ្នាំប្រសិនបើចាំបាច់ ។

៣-ពង្រឹងពង្រីកសមត្ថភាពកិច្ចសហប្រតិបត្តិការ និងភាពរលូន រវាងគ្រប់កម្លាំងអន្តរាគមន៍សំរាប់ការពារនីមួយៗក្នុងហេដ្ឋារចនាសម្ព័ន្ធទាំង 3 ។

៤-ហេដ្ឋារចនាសម្ព័ន្ធទី 1 រួមមានផែនការការពារគោលដៅ និងមូលដ្ឋានអគ្គិសនី, រដ្ឋាករទឹក, ផ្លូវជាតិ – ផ្លូវដែក – អាគាររដ្ឋ – អាគារឯកជន ។

-ហេដ្ឋារចនាសម្ព័ន្ធទី 2 រួមមានផែនការការពារព្រលានយន្តហោះ – កំពង់ផែ – នាវាចរ (សមុទ្រនិងទន្លេ) – ពិធីបុណ្យ អង្គប្រជុំជាតិ អន្តរជាតិ គណៈប្រតិភូ – ស្ថានទូត កុងសុល និវេសដ្ឋានឯកអគ្គរដ្ឋទូត – សាលាអន្តរជាតិ (ដែលមានកូនសិស្សបរទេសសិក្សា) ។

-ហេដ្ឋារចនាសម្ព័ន្ធទី 3 រួមមានផែនការធ្វើឱ្យកាន់តែល្អប្រសើរអំពីទិដ្ឋភាពច្បាប់ – ការអនុវត្តន៍អនុសញ្ញា សន្ធិសញ្ញា និងកតិកាសញ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងអំពើភេរវកម្ម និងធ្វើរបាយការណ៍ជូន អ.ស.ប ព្រមទាំងសិក្សាការធ្វើផែនការការពារៈ

+ប្រឆាំងការលាងលុយកខ្វក់

+ប្រឆាំងការធ្វើលិខិត ឯកសារក្លែងក្លាយ ការជួញដូរមនុស្ស

+ប្រឆាំងបទឧក្រិដ្ឋផ្សេងៗទៀត រាប់ទាំងគ្រឿងញៀន

៥-ដឹកនាំ និងរៀបចំការងារសមយុទ្ធ សំដៅឱ្យគ្រប់ផ្នែក និងកម្លាំងនានាដែលពាក់ព័ន្ធអាចប្រតិបត្តិស៊ីសង្វាក់ មានប្រសិទ្ធភាព និងស្ទាត់ជំនាញមុនមានព្រឹត្តិការណ៍កើតឡើង ។

៦-ទំនាក់ទំនងផ្លាស់ប្តូរព័ត៌មានទៅគណៈបញ្ជាការឯកភាពខេត្តក្រុង សហការរៀបចំគំរោងការពារលំអិត គំរោងដោះស្រាយលំអិតសំរាប់ករណីភេរវកម្មកើតឡើងនីមួយៗ ។

៧-ព្យាករណ៍ពីលទ្ធភាពអ្វីខ្លះដែលយើងនឹកមិនដល់ ហើយអាចភេរវករនឹកឃើញធ្វើបាននិងសិក្សាស្រាវជ្រាវរកចំណុចចន្លោះប្រហោងរបស់សមត្ថកិច្ច ដើម្បីស្នើសុំវិធានការ បំពេញ ពង្រឹង។

៨-រៀបចំខ្លឹមសារឃោសនាអប់រំសំដៅលើកកំពស់ស្មារតីប្រុងប្រយ័ត្ន ប្រយុទ្ធប្រឆាំងអំពើភេរវកម្ម។ សិក្សាទិដ្ឋភាពច្បាប់ អនុសញ្ញា សន្ធិសញ្ញា កត្តិកសញ្ញាអន្តរជាតិពាក់ព័ន្ធដល់អំពើភេរវកម្មនិងធ្វើរបាយការណ៍ជូនអង្គការសហប្រជាជាតិតាមការកំណត់ ។

## ជំពូក ៤

## នាយកដ្ឋានពិសេស

**មាត្រា ១១:-**

**នាយកដ្ឋានពិសេសមានភារកិច្ចដូចតទៅៈ**

១- បណ្តុះបណ្តាល ហ្វឹកហាត់ គ្រប់គ្រង និងបញ្ជាកម្លាំងពិសេសប្រឆាំងភេរវកម្ម (កពបភ) ថ្នាក់ជាតិ រួមមានៈ

- កម្លាំងវាយលុកលើភេរវករ (CTAF) និងកម្លាំងវាយលុកលើភេរវករថ្នាក់ជាតិ (NCTAF) គ្រប់ប្រភេទ
- កម្លាំងដោះស្រាយគ្រឿងផ្ទុះច្នៃប្រឌិតភេរវកម្ម (IED) - គីមី - វិទ្យុសកម្ម - នុយក្លេអ៊ែរ
- កោសល្យវិច័យភេរវកម្ម និងមន្ទីរពិសោធន៍បំរើឱ្យការងារប្រឆាំងភេរវកម្ម

២-ត្រួតពិនិត្យគុណភាពបណ្តុះបណ្តាល ហ្វឹកហ្វឺនកម្លាំងពិសេសប្រឆាំងភេរវកម្មតាមអង្គភាពនានា ។

៣-គ្រប់គ្រងដឹកនាំបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម ដែលមានទីតាំងកណ្តាលនៅកងអន្តរាគមន៍នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងមូលដ្ឋានផ្សេងៗទៀតរបស់ខ្លួន ។

៤-ផ្តល់ឧបករណ៍សំភារៈសំលៀកបំពាក់ពិសេស អាវុធជំនាញដល់កម្លាំងពិសេសប្រឆាំងភេរវកម្ម។

៥-ស្នើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល តាមរយៈប្រធាន គជបភ អំពីឯកសណ្ឋាន - រូបសញ្ញា - ឋានន្តរស័ក្តិ សំរាប់កម្លាំងពិសេសប្រឆាំងភេរវកម្ម។

៦-គ្រោងថវិកាប្រចាំឆ្នាំសំរាប់ដំណើរការនិងស្នើសុំប្រាក់ឧបត្ថម្ភពិសេសសំរាប់កម្លាំងប្រឆាំងភេរវកម្ម ។

៧-បំពេញការងារចារកម្មបំរើឱ្យកម្លាំងពិសេស និងការងារចរចារដោះចំណាប់ខ្មាំងបំរើឱ្យប្រតិបត្តិការ ។

**មាត្រា ១២:-**

ប្រធាននាយកដ្ឋានពិសេស គឺជាអនុប្រធានប្រចាំការមួយរូបនៃលេខាធិការដ្ឋាន គជបភ ហើយក៏ជាមេបញ្ជាការនៃបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម នៃគជបភ ។

បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្មនៃគជបភ មានមេបញ្ជាការមួយរូប មេបញ្ជាការរងមួយចំនួនតាមការចាំបាច់ និងមានសេនាធិការ និងផ្នែកភ័ស្តុភារ និងផ្នែកនានាសំរាប់ជួយការងារដល់មេបញ្ជាការ ។

មេបញ្ជាការ នៃបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម នៃគជបភ មានឋានន្តរស័ក្តិ វរសេនីយ៍ឯក ។

មេបញ្ជាការរង នៃបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម នៃគជបភ មានឋានន្តរស័ក្តិ វរសេនីយ៍ទោ ។

មេបញ្ជាការ និង មេបញ្ជាការរង នៃបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម នៃគជបភ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន គជបភ ។

**មាត្រា ១៣:~**

កម្លាំងវាយលុកលើភេរវករ (CTAF) នៃកម្លាំងពិសេសប្រឆាំងភេរវកម្ម ត្រូវទទួលស្គាល់ដោយសេចក្តីសំរេចរបស់ប្រធាន គជបភ តាមសំណើរបស់ប្រធាននាយកដ្ឋានពិសេស ។

កម្លាំងពិសេសប្រឆាំងភេរវកម្មថ្នាក់ជាតិរបស់បញ្ជាការដ្ឋាននៃ គជបភ ត្រូវជ្រើសរើសចេញពីយោធា និងកងរាជអាវុធហត្ថ ហើយក្រោយពីបណ្តុះបណ្តាលហ្វឹកហាត់ អ្នកដែលជាប់ពិន្ទុទើបត្រូវបានប្រធាន គជបភ ទទួលស្គាល់ជាកម្លាំងវាយលុកលើភេរវករ NCTAF តាមសំណើរបស់ប្រធាននាយកដ្ឋានពិសេស ហើយត្រូវទទួលឋានន្តរស័ក្តិថ្មីរបស់បញ្ជាការដ្ឋាន ។

តាមសំណើរបស់ប្រធាននាយកដ្ឋានពិសេស ប្រធាន គជបភ ចេញសេចក្តីសំរេចទទួលស្គាល់ការចប់អាណត្តិធ្វើជាកម្លាំងពិសេសប្រឆាំងភេរវកម្ម ហើយកម្លាំងទាំងនោះត្រូវវិលទៅអង្គភាពដើម ក្រោមការជ្រោមជ្រែងរៀបចំឱ្យបានល្អពីសំណាក់ប្រធាននាយកដ្ឋានពិសេស និងសាមីអង្គភាព ។ ឋានន្តរស័ក្តិចាស់ត្រូវបានរក្សា ឬត្រូវតម្លើងប្រសិនបើគ្រប់ឆ្នាំត្រូវឡើង ឬបើត្រូវបានតម្លើងជាស្វ័យប្រវត្តិនៅពេលអនុវត្តការងារនៅបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម ។

**មាត្រា ១៤:~**

កម្លាំងពិសេសប្រឆាំងភេរវកម្មថ្នាក់ជាតិ មកពីអង្គភាពយោធា ឬអង្គភាពកងរាជអាវុធហត្ថណា ត្រូវរក្សាក្របខ័ណ្ឌនៅក្នុងអង្គភាពនោះ លើកលែងតែមានសំណើពីប្រធាននាយកដ្ឋានពិសេសមកប្រធាន គជបភ សុំផ្ទាច់អ្នកទាំងនោះមកក្នុងក្របខ័ណ្ឌនាយកដ្ឋានពិសេស ។ សាមីអង្គភាពដើមនៅបន្តបើកប្រាក់បៀវត្សរ៍ ប្រាក់ឧបត្ថម្ភហូបចុក សំលៀកបំពាក់ និងរបបផ្សេងៗទៀតជាធម្មតា មកឱ្យតាមរយៈផ្នែកភ័ស្តុភារនៃបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម ។

នាយកដ្ឋានពិសេសផ្តល់ការបណ្តុះបណ្តាល និងការហ្វឹកហាត់ពិសេស អាវុធ សំលៀកបំពាក់ និងឧបករណ៍ពិសេសជំនាញសំរាប់ការប្រឆាំងភេរវកម្ម ។

នាយកដ្ឋានពិសេសផ្តល់ប្រាក់ឧបត្ថម្ភពិសេសដល់មេបញ្ជាការ - មេបញ្ជាការរង និងអ្នកដឹកនាំផ្សេងៗទៀត រហូតដល់សមាជិកក្នុងបញ្ជាការដ្ឋានជាតិ ហើយបរិមាណទឹកប្រាក់ឧបត្ថម្ភពិសេស និងរបបពិសេសផ្សេងៗទៀតនឹងកំណត់ដោយសេចក្តីសម្រេចដោយឡែក ។

## ជំពូក ៥

## អវសានបញ្ញត្តិ

**មាត្រា ១៥:~**

រាល់អនុក្រឹត្យ និងសេចក្តីសំរេចពីមុនមកដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦:~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន គជបភ លេខាធិការដ្ឋាន គជបភ និងគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន។

**មាត្រា ១៧:~**

អនុក្រឹត្យនេះ ចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- ឯកសារ – កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:..២០...អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- តាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## ស ម្រេ ច

**មាត្រា១ .-** ត្រូវបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) មួយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ។

**មាត្រា២ .-** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពមន្ត្រីជាន់ខ្ពស់តំណាងឱ្យក្រសួង ស្ថាប័ន ដូចខាងក្រោម :

១- តំណាងធនាគារជាតិនៃកម្ពុជា.................................................ប្រធាន

២- តំណាងក្រសួងយុត្តិធម៌ .................................................សមាជិក

៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី.................................................សមាជិក

៤- តំណាងក្រសួងមហាផ្ទៃ.................................................សមាជិក

៥- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.................................................សមាជិក ។

**មាត្រា៣ .-** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលមានឋានៈស្មើអគ្គនាយក ។

**មាត្រា៤ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែល ពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា២ និងមាត្រា៣ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី២៩ ខែមករា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១ .អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

-បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់បេសកកម្ម តួនាទី ភារកិច្ច ព្រមទាំងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ. និងតួនាទី ភារកិច្ចរបស់នាយកដ្ឋាននានា ។

## ជំពូកទី ២

## បេសកកម្ម និងភារកិច្ច

**មាត្រា ២.-**

អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ. មានបេសកកម្ម ÷

-ការពារ ថែរក្សា អភិរក្ស និងលើកតម្លៃឧទ្យានបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទព្រះវិហារ

-គិតគូរ និងអនុវត្តឱ្យបានសម្រេចនូវផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ទាំង ៤ ដែលបានកំណត់ដោយបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ និងអនុក្រឹត្យ លេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការគ្រប់គ្រងតំបន់រមណីយដ្ឋាន ប្រាសាទព្រះវិហារ ព្រមទាំងទប់ស្កាត់បទល្មើសព្រៃឈើ គ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមដំណាក់កាលនីមួយៗ ដើម្បីធ្វើឱ្យបានសម្រេចនូវការងារដែលបានកំណត់ក្នុងផែនការសកម្មភាព និងកម្មវិធីរៀបចំអភិវឌ្ឍន៍ទេសចរណ៍ដូចបានរៀបរាប់ខាងលើ

-រួមចំណែកក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលនៅក្នុងតំបន់ប្រាសាទព្រះវិហារ

-សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្តល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងទាំងឡាយដែលទាក់ទងនឹងបេសកកម្មរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ

-សហការជាមួយក្រសួង ស្ថាប័ន មូលនិធិ អង្គការ សមាគមជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលមានគោលបំណងស្របនឹងទិសដៅរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ ។

ℓ

**មាត្រា ៣.-**

អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ. មានមុខងារ និងភារកិច្ចដូចតទៅ ÷

-គិតគូរ និងចាត់ចែងអនុវត្តនូវរាល់ផែនការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងលើការថែរក្សា និងការពារប្រាសាទនានាក្នុងតំបន់ប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ

-ធ្វើអន្តរាគមន៍ចាំបាច់ និងបន្ទាន់ដើម្បីធានាកិច្ចការពារ និងស្រោចស្រង់រមណីយដ្ឋានប្រាសាទព្រះវិហារ

-បង្កើតឱ្យមានអង្គភាពឆ្មាំប្រាសាទ ដើម្បីបង្ការ ថែរក្សា ការពារ ឬគ្រប់គ្រងប្រាសាទនានារួមទាំងទេសភាព និងបរិស្ថានដែលនៅជុំវិញប្រាសាទទាំងនោះ

-ធ្វើការស្ទង់មើល និងធ្វើកំណាយបុរាណវិទ្យា

-រួមចំណែកបង្កើនចំណេះដឹង និងការស្រាវជ្រាវ ដើម្បីចងក្រងឯកសារអំពីវប្បធម៌ខ្មែរនៅតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-គិតគូរ និងចាត់ចែងអនុវត្តនូវផែនការសម្រាប់រយៈពេលមធ្យម និងរយៈពេលវែងក្នុងគោលបំណងលើកតម្លៃជំរុញផ្សព្វផ្សាយ និងគ្រប់គ្រងការធ្វើសកម្មភាពពាណិជ្ជកម្មនៃតំបន់ឧទ្យានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ដើម្បីបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ និងផ្តល់ព័ត៌មានដល់ភ្នាក់ងារ និងអ្នកប្រកបមុខរបរទេសចរណ៍

-ធានាការគ្រប់គ្រងនិងការប្រើប្រាស់កម្រៃបានមកពីការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិជាធរមាន និងវិធានអន្តរជាតិនានា

-រៀបចំចំណតរថយន្ត មធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ តូប ស្តង់លក់ដូរវត្ថុអនុស្សាវរីយ៍ លក់គេសជ្ជៈ ស្ថានីយប៉ុស្តិ៍នគរបាលការពារបេតិកភណ្ឌ និងឆ្មាំប្រាសាទ បង្គន់ បន្ទប់ទឹក និងរថយន្តសង្គ្រោះបន្ទាន់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធដើម្បីរៀបចំអភិវឌ្ឍន៍តំបន់រណប ( តំបន់ ៣) ឱ្យបានល្អប្រសើរ និងមានភាពសមរម្យដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិជាធរមាន ព្រមទាំងយកចិត្តទុកដាក់ពីផលប៉ះពាល់ទៅលើបរិស្ថានដែលបណ្តាលមកពីកំណើនប្រជាពលរដ្ឋ និងវិធានអន្តរជាតិស្តីពីការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព

-ចេញលិខិតអនុញ្ញាតរុះរើ និងសាងសង់សំណង់នានា ព្រមទាំងលិខិតបញ្ជាឱ្យរុះរើចំពោះសំណង់គ្មានច្បាប់អនុញ្ញាតដែលប៉ះពាល់ធ្ងន់ធ្ងរក្នុងតំបន់ការពារដែលបានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

-សិក្សាពីផលប៉ះពាល់ និងវាយតម្លៃលើគម្រោងវិនិយោគវិស័យទេសចរណ៍ ធ្វើការតាមដាន ឃ្លាំមើលតាមរយៈនៃការរៀបចំព្យាករណ៍ជាប្រចាំសម្រាប់រយៈពេលកំណត់នីមួយៗ

*ﾉ*

-កំណត់ជ្រើសរើស និងចាត់ចែងអនុវត្តគម្រោងវិនិយោគវិស័យទេសចរណ៍ ដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិ និងវិធាននានាជាធរមាន

-រៀបចំកិច្ចសន្យាជាមួយវិនិយោគិន និងសម្បទានិក ព្រមទាំងធ្វើការដោះស្រាយរាល់កិច្ចការវិវាទទាំងឡាយដោយអនុលោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិជាធរមាន និងវិធានអន្តរជាតិនានា

-រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ខេត្តព្រះវិហារដោយបង្កើនការងារ ជំរុញឱ្យមានកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងពង្រឹងសមត្ថភាពបម្រើការងាររបស់ប្រជាជននៅតំបន់នេះ និងតំបន់ផ្សេងៗទៀតដែលពាក់ព័ន្ធ

-ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា ដែលផ្តល់ការរីកចម្រើនដល់រមណីយដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងបរិស្ថានដោយអនុលោមតាមគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រាជរដ្ឋាភិបាល

-រៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យគុណភាពលើការធ្វើអាជីវកម្ម និងសេវាកម្មនានាក្នុងគោលដៅការពារបរិស្ថាន និងអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់ខេត្តព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-ទទួលការងារពិធីការ និងរៀបចំមគ្គុទ្ទេសក៍សម្រាប់ទទួលគណៈប្រតិភូជាន់ខ្ពស់ជាតិ និងអន្តរជាតិដែលចូលមកទស្សនាតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-បង្ក្រាបបទល្មើសព្រៃឈើ គ្រប់គ្រងដីធ្លី និងទប់ស្កាត់អំពើអនាធិបតេយ្យនៅតំបន់ប្រាសាទព្រះវិហារ និងកសាងសំណុំរឿងបញ្ជូនជនល្មើសទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន

-ធ្វើរបាយការណ៍តាមរយៈប្រធាន អ.ជ.ព.វ ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ និងសភាពការណ៍ ព្រមទាំងវិធានការនានាដែលអាជ្ញាធរជាតិប្រកាន់យក ផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងធ្វើរបាយការណ៍តាមរយៈប្រធាន អ.ជ.ព.វ ស្តីពីស្ថានភាពចំណូល និងចំណាយរបស់អាជ្ញាធរជាតិជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤.-**

អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ. ស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាន អ.ជ.ព.វ និងក្រុមប្រឹក្សាភិបាល មួយដែលមានអគ្គនាយក ០១ រូប ទទួលខុសត្រូវរួមក្នុងការដឹកនាំការងាររបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ ។

អគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ. មានអគ្គនាយករងមួយចំនួនជាជំនួយការ ។

**មាត្រា ៥.-**

ការកំណត់ និងការបែងចែកភារកិច្ចរបស់អគ្គនាយក និងអគ្គនាយករងរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន អ.ជ.ព.វ ។

**មាត្រា ៦.-**

អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក និងមានកញ្ចប់ថវិកាជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៧.-**

អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ. មានរចនាសម្ព័ន្ធ ដូចតទៅ ÷

១. នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច ទំនាក់ទំនងសាធារណៈ ផែនការ និងនីតិកម្ម ។

២. នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យា ។

៣. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ តំបន់ប្រាសាទព្រះវិហារ ។

៤. នាយកដ្ឋាននគរូបនីយកម្ម អភិវឌ្ឍន៍តំបន់ប្រាសាទព្រះវិហារ និងប្រជាសាស្ត្រ ។

៥. នាយកដ្ឋានបរិស្ថាន ព្រៃឈើ និងទឹក ។

៦. នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ ។

**មាត្រា ៨.-**

នាយកដ្ឋានទីមួយៗនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ. ស្ថិតក្រោមការដឹកនាំ និងទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋាន ០១ រូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់នាយកដ្ឋាននានា

**មាត្រា ៩.-**

នាយកដ្ឋានរដ្ឋបាល ហិរញ្ញកិច្ច ទំនាក់ទំនងសាធារណៈ ផែនការ និងនីតិកម្ម មានតួនាទី និងភារកិច្ច ដូចតទៅ ÷

-ធ្វើទំនាក់ទំនង និងសហការជាមួយសមាជិកក្រុមប្រឹក្សាភិបាល អ.ជ.ព.វ ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាន

-ទទួលលិខិតចូល ពិនិត្យ បែងចែកលិខិតតាមខ្លឹមសារជូនអគ្គនាយក អគ្គនាយករង នាយកដ្ឋាននានា ចំណុះអគ្គនាយកដ្ឋាននៃ អ.ជ.ព.វ និងធ្វើចេញនូវលិខិតរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ ជូនក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធក្រោយពីមានការសម្រេចពីប្រធាន អ.ជ.ព.វ

-គ្រប់គ្រង និងអនុវត្តសិទ្ធិអំណាចតាមឋានានុក្រមលើបុគ្គលិកទាំងអស់របស់អគ្គនាយកដ្ឋាន នៃ អ.ជ.ព.វ

-រៀបចំស្ថិតិលើការគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិកព្រមទាំងធ្វើតារាងការងារដែលអគ្គនាយកដ្ឋាននៃ អ.ជ.ព.វ បានអនុវត្តកន្លងមក និងត្រូវអនុវត្តបន្តនៅពេលអនាគត

-អនុវត្តតម្លៃតាមតារាងកំណត់ប្រាក់បៀវត្សរ៍ ប្រាក់កម្រៃ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់ការងារនីមួយៗ របស់មន្ត្រីរាជការ និងបុគ្គលិកនៅអគ្គនាយកដ្ឋាននៃអ.ជ.ព.វ

ℒ

-រៀបចំជាមួយនាយកដ្ឋានបច្ចេកទេសនានានូវកម្មវិធីស្តីពីការកំណត់តំណែងឯកទេស និងការបែងចែកធនធានមនុស្ស

-រៀបចំគម្រោងជាមួយនាយកដ្ឋានបច្ចេកទេស ពាក់ព័ន្ធស្តីពីតម្រូវការសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីរាជការ និងបុគ្គលិក

-រៀបចំគម្រោងជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធនូវសំណើសុំថវិកា ឬការផ្តល់ថវិកាសម្រាប់ការងារបន្ទាន់

-ពិនិត្យ និងតាក់តែងកិច្ចសន្យាជាមួយវិនិយោគិន និងសម្បទានិក

-ធ្វើការតាមដាន និងឃ្លាំមើលការអនុវត្តកិច្ចសន្យាដែលទាក់ទងនឹងកិច្ចការវិនិយោគ និងសម្បទាន

-គ្រប់គ្រងផ្ទាល់ការធ្វើអាជីវកម្មនានា ឬតាមដានឃ្លាំមើលជាអចិន្ត្រៃយ៍លើការងារអាជីវកម្មរបស់ក្រុមហ៊ុនសម្បទាននានាដើម្បីធានាការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព

-ប្រមូលប្រាក់ចំណូល និងចាត់ចែងចំណាយ

-រក្សាទុក និងចាត់ចែងការប្រើប្រាស់មូលនិធិ និងរូបិយវត្ថុ

-កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកនូវលិខិតយុត្តិការបណ្ណសារ

-រៀបចំគណនីហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ

-គ្រប់គ្រង វែបសាយ របស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ

-រៀបចំផែនការមេក្នុងការអភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានព្រះវិហារ ដើម្បីធ្វើការផ្សព្វផ្សាយទំនាក់ទំនងជាមួយវិនិយោគិនផ្នែកឯកជនឱ្យចូលមកវិនិយោគនៅក្នុងតំបន់អភិវឌ្ឍន៍ (តំបន់ ៣ ) និងក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-រៀបចំផែនការកសាងច្បាប់ និងបទប្បញ្ញត្តិ សម្រាប់គ្រប់គ្រងតំបន់រមណីយដ្ឋានព្រះវិហារ

-សហការសម្របសម្រួលក្នុងការរៀបចំព័ត៌មានស្តីពីផែនការសកម្មភាពការងាររបស់នាយកដ្ឋាននីមួយៗ និងកម្មវិធីការងារដែលនាយកដ្ឋាននានាកំពុងដំណើរការ

-ធ្វើរបាយការណ៍សរុប តាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនិងការងាររបស់ខ្លួនជូនប្រធាន អ.ជ.ព.វ ។

## មាត្រា ១០.-

នាយកដ្ឋានរមណីយដ្ឋាន និងបុរាណវិទ្យា មានតួនាទី និងភារកិច្ចដូចតទៅ÷

-ធ្វើផែនការ និងដាក់ឱ្យអនុវត្តនូវការងាររៀបចំផ្សេងៗ នៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារដែលទាក់ទងនឹងប្រាសាទ និងទេសភាពនានាដែលមានសារៈសំខាន់ផ្នែកវប្បធម៌

-ធ្វើផែនការមេសម្រាប់ការពារ និងថែរក្សាបរិស្ថានប្រវត្តិសាស្ត្រក្នុងតំបន់ឧទ្យានប្រាសាទព្រះវិហារ ដោយរួមបញ្ចូលទាំងឯកសារស្ថានភាពប្រាសាទនានា និងផែនទីបង្ហាញកន្លែងគ្រោះថ្នាក់

-ថែរក្សា ការពារជាប្រចាំ យ៉ាងទៀងទាត់ និងយូរអង្វែងចំពោះរមណីយដ្ឋានដែលបានទទួលចំណាត់ថ្នាក់ជាបេតិកភណ្ឌពិភពលោក

-សហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ប្រាសាទព្រះវិហារដោយផ្អែកទៅលើសមត្ថកិច្ចនាយកដ្ឋានជំនាញនីមួយៗដោយយកចិត្តទុកដាក់លើការថែទាំ ការដាក់ផ្លាកសញ្ញាធ្វើចរាចរ ការដាក់ផ្លាកសញ្ញាផ្សេងៗដែលចាំបាច់ ការរៀបចំចំណតរថយន្ត មធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ ការកំណត់តូប ស្តង់លក់ដូរវត្ថុអនុស្សាវរីយ៍ និងភេសជ្ជៈ ស្នាក់ការប៉ុស្តិ៍នគរបាលការពារបេតិកភណ្ឌ បង្គន់ និងបន្ទប់ទឹកជាដើម ដើម្បីធានាឱ្យមានសោភ័ណភាពល្អប្រសើរដល់តំបន់ខេត្តព្រះវិហារ និងបរិវេណនានានៃតំបន់នោះ

-រៀបចំសេចក្តីព្រាងឯកសារ ស្តីពីដីធ្លីដែលស្ថិតនៅក្នុងគម្រោងរៀបចំអភិវឌ្ឍន៍តំបន់ខេត្ត ព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យគម្រោងអាចអនុវត្តបាន

-រៀបចំផែនការ ការស្ទង់ពិនិត្យមើល និងកំណាយបុរាណវិទ្យា ព្រមទាំងចាត់វិធានការសម្រាប់បង្ការ ឬសង្គ្រោះតាមការចាំបាច់

-បង្កើតក្រុមចល័តដែលមានសមត្ថភាព និងមានឧបករណ៍ សម្ភារៈសមស្របដើម្បីរៀបចំថែទាំ និងតាមដានផ្នែកបុរាណវិទ្យា និងការគ្រប់គ្រងរមណីយដ្ឋាន

-ទទួលបណ្តុះបណ្តាលបុរាណវិទូ ស្ថាបត្យករ និងក្រុមអភិរក្សដែលទទួលបន្ទុកការងារនៅតំបន់ឧទ្យានប្រាសាទព្រះវិហារ

-គ្រប់គ្រង និងដឹកនាំឆ្មាំប្រាសាទ កម្លាំងកម្មករសំអាតឧទ្យាន និងកម្មករជំនាញនានាក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-កំណត់ និងប្រគល់ទីតាំងរៀបចំពិធីផ្សេងៗក្នុងតំបន់ប្រាសាទព្រះវិហារ និងតាមដានការប្រព្រឹត្តទៅនៃពិធីទាំងនោះ

-ធ្វើការសិក្សាវិស្វកម្មវិទ្យា

-ស្រាវជ្រាវកុលាលភាជន៍

-រៀបចំប្លង់ប្រើប្រាស់ដីធ្លីក្នុងតំបន់ប្រាសាទព្រះវិហារ

-ចុះបញ្ជីសារពើភណ្ឌប្រាសាទទាំងអស់ក្នុងតំបន់ប្រាសាទព្រះវិហារដែលជាបេតិកភណ្ឌ

-ស្រាវជ្រាវបេតិកភណ្ឌរូបិយ និងអរូបិយ

-គ្រប់គ្រងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ជីអាយអេស

-ដឹកនាំ និងគ្រប់គ្រងកិច្ចដំណើរការរបស់មណ្ឌលអន្តរជាតិតម្កល់ឯកសារប្រាសាទព្រះវិហារ

-ស្តារ និងជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាអាទិ៍ ផ្លូវ ស្ពាន លូ និងប្រឡាយក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងរមណីយដ្ឋានផ្សេងៗទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ អ.ជ.ព.វ

-ធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធ និងការងាររបស់ខ្លួនជូនប្រធាន អ.ជ.ព.វ។

**មាត្រា ១១.-**

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ តំបន់ប្រាសាទព្រះវិហារមានតួនាទី និងភារកិច្ចដូចតទៅ ÷

-រៀបចំទិសដៅអភិវឌ្ឍន៍វិស័យទេសចរណ៍សម្រាប់រយៈពេលមធ្យម និងរយៈពេលវែងនៅតំបន់ប្រាសាទព្រះវិហារដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធឱ្យស្របទៅនឹងគោលនយោបាយទេសចរណ៍របស់រាជរដ្ឋាភិបាល

-រួមចំណែកក្នុងការលើកតម្លៃរមណីយដ្ឋាន និងប្រាង្គប្រាសាទនានាក្នុងតំបន់ខេត្តព្រះវិហារ

-រៀបចំវិធាន ស្តីពីការគ្រប់គ្រងទេសចរណ៍នៅក្នុងតំបន់ឧទ្យានប្រាសាទព្រះវិហារ

-គ្រប់គ្រងពិធីនានាដែលរៀបចំក្នុងតំបន់ប្រាសាទព្រះវិហារ

-រកចំណូលផ្សេងៗទៀតដែលបានមកពីការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការលក់ផលិតផលបន្ទាប់បន្សំទាក់ទងទៅនឹងរូបភាពប្រាសាទព្រះវិហារ

-ឃោសនាផ្សព្វផ្សាយ សិក្សាទីផ្សារ និងផ្តល់ព័ត៌មានសម្រាប់ទាក់ទាញភ្ញៀវទេសចរ ទាក់ទងទៅនឹងប្រាង្គប្រាសាទ បរិស្ថានធម្មជាតិ និងវប្បធម៌ក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-ទទួលបណ្តុះបណ្តាល និងបំប៉ន់វិជ្ជាបន្ថែមដល់មគ្គុទ្ទេសក៍ទេសចរណ៍សម្រាប់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

-ធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធ និងការងាររបស់ខ្លួនជូនប្រធាន អ.ជ.ព.វ។

**មាត្រា ១២.-**

នាយកដ្ឋាននគរូបនីយកម្ម អភិវឌ្ឍន៍តំបន់ប្រាសាទព្រះវិហារ និងប្រជាសាស្ត្រមានតួនាទី និងភារកិច្ចដូចតទៅ ÷

- ចូលរួមសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធដើម្បីគិតគូរ និងលើកផែនការអភិវឌ្ឍន៍វិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព តុល្យភាព និងសមាហរណភាពក្នុងតំបន់ប្រាសាទព្រះវិហារព្រមទាំងតំបន់ពាក់ព័ន្ធផ្សេងទៀត

-រៀបចំគម្រោងប្លង់មេសម្រាប់នគរូបនីយកម្មនៃតំបន់អភិវឌ្ឍន៍ (តំបន់ ៣ ) និងកំណត់ទិសដៅសម្រាប់បែបបទប្រើប្រាស់ដីធ្លី និងបទដ្ឋានសម្រាប់សាងសង់នៅតំបន់ប្រាសាទព្រះវិហារដោយសហការជាមួយអាជ្ញាធរដែនដី មន្ទីរជំនាញពាក់ព័ន្ធរួចដាក់ជូនប្រធាន អ.ជ.ព.វ ពិនិត្យ និងសម្រេចតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ

-ពិនិត្យ និងផ្តល់យោបល់លើការចេញលិខិតអនុញ្ញាតឱ្យរុះរើ និងសាងសង់សំណង់នានាសម្រាប់តំបន់ការពារដែលបានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ និងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ រួចដាក់ជូនប្រធាន អ.ជ.ព.វ. ពិនិត្យ និងសម្រេចតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ

-តាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍លើការស្ថាបនាដោយយកចិត្តទុកដាក់ក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗជាធរមាន

- វិភាគ និងវាយតម្លៃអំពីផលប៉ះពាល់បណ្តាលមកពីគម្រោងវិនិយោគ និងអភិវឌ្ឍន៍ទាំងឡាយក្នុងតំបន់រមណីយដ្ឋានតំបន់ប្រាសាទព្រះវិហារ

- រួមចំណែកក្នុងការកំណត់មុខសញ្ញានៃគម្រោងវិនិយោគ និងអភិវឌ្ឍន៍វិស័យទេសចរណ៍ និងការអនុវត្តគម្រោងទាំងនោះសម្រាប់តំបន់ប្រាសាទព្រះវិហារ

- ធ្វើការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅក្នុងតំបន់ខេត្តព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

- តាមដានការប្រែប្រួលនៃកំណើន និងកម្រិតជីវភាពរស់នៅរបស់ប្រជាជន ដើម្បីបង្កើនការរៀបរំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជូនប្រជាជននៅក្នុងតំបន់ខេត្តព្រះវិហារ

- ធ្វើសមាហរណកម្មវិស័យកសិ-ទេសចរណ៍ ដោយផ្តួចផ្តើមឱ្យមានកសិកម្មបែបជីវសាស្ត្រ និងរៀបចំឱ្យមានខ្សែចង្វាក់ទីផ្សារសម្រាប់ផលិតផលកសិកម្ម

-ធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនិងការងាររបស់ខ្លួនជូនប្រធាន អ.ជ.ព.វ។

**មាត្រា ១៣.-**

នាយកដ្ឋានបរិស្ថាន ព្រៃឈើ និងទឹក មានតួនាទី និងភារកិច្ចដូចតទៅ ÷

-ធ្វើការគ្រប់គ្រងទឹក ទាំងបរិមាណ និងគុណភាពនៅតំបន់ប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-សិក្សាអំពីរុក្ខជាតិ និងជីវិតសត្វនៅក្នុងតំបន់ប្រាសាទព្រះវិហារ និងនៅខេត្តព្រះវិហារ

-ធ្វើការគ្រប់គ្រងព្រៃឈើនៅក្នុងឧទ្យានប្រាសាទព្រះវិហារ និងឧទ្យានផ្សេងៗទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ អ.ជ.ព.វ រួមមានការអភិរក្ស ថែទាំ និងការដាំកូនឈើឡើងវិញ

-ធ្វើការសិក្សាអំពីបរិស្ថាន បរិយាកាស និងអាកាសធាតុដោយរៀបចំឱ្យមានសំណង់ ឧតុនិយមអាកាសធាតុ ប្រមែប្រមូលរាល់ទិន្នន័យដែលមានស្រាប់នៅក្នុងតំបន់ តាមដានការប្រែប្រួលអាកាសធាតុ ឥទ្ធិពលដែល

មានទៅលើជលសាស្ត្រ និងកសិកម្ម និងការបំពុលបរិស្ថាន ការបំពុលទឹក ការបំពុលខ្យល់ ព្រមទាំងការរំខានដោយសំឡេង

-ធ្វើការសិក្សាដីសម្រាប់កសិកម្ម និងព្រៃឈើ ដើម្បីប្រើប្រាស់ឱ្យសមស្របតាមគុណភាពប្រភេទដីនីមួយៗក្នុងតំបន់ប្រាសាទព្រះវិហារ

-ធ្វើការសិក្សាអំពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពដោយសហការសិក្សារួមគ្នាជាមួយនាយកដ្ឋានជំនាញនានាទៅលើផ្នែកខាងលើដី និងក្រោមដី អាកាសធាតុ រុក្ខជាតិ និងប្រាសាទនានា ។

## មាត្រា ១៥.-

នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការមានតួនាទី និងភារកិច្ច ដូចតទៅ ÷

-ការពារ និងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ផ្សេងទៀតដែលគ្រប់គ្រងដោយ អ.ជ.ព.វ

-ក្តាប់បានផែនទីប្លង់មេនៃតំបន់ទាំង ៤ ដែលគ្រប់គ្រងដោយ អ.ជ.ព.វ ហើយលើកផែនការ និងវិធានការក្នុងការចាត់ចែងកងកម្លាំងឱ្យការពារនៅតាមគោលដៅនានាដែលបានកំណត់

-ក្តាប់សភាពការណ៍ និងស្រាវជ្រាវរកឱ្យឃើញនូវបទល្មើសផ្សេងៗ និងធ្វើជាស្នូលផ្តល់ព័ត៌មានជូនដល់ អ.ជ.ព.វ

-រៀបចំឯកសារ និងបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធនឹងបទល្មើសក្នុងតំបន់អភិរក្សជូន អ.ជ.ព.វ ដើម្បីមានវិធានការតាមផ្លូវច្បាប់

-សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ ដើម្បីធ្វើប្រតិបត្តិការទប់ស្កាត់ និងបំបាត់បទល្មើសដែលកើតមានក្នុងតំបន់អភិរក្ស

-ត្រួតពិនិត្យ ឃ្លាំមើល និងទប់ស្កាត់ជាប្រចាំលើការសាងសង់សំណង់ក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ

-សហការជាប្រចាំជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នគរបាល កងរាជអាវុធហត្ថ និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការទប់ស្កាត់ និងមានវិធានការចំពោះការកាប់បំផ្លាញព្រៃឈើ ការរំលោភបំពាន ការព័ទ្ធរបងយកដី ការសាងសង់លំនៅឋាន និងសំណង់អគារដែលគ្មានច្បាប់អនុញ្ញាតនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ដែលត្រូវការពារដោយ អ.ជ.ព.វ

-សហការជាមួយនគរបាលការពារបេតិកភណ្ឌដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើគាស់ រុករក និងលួចវត្ថុបុរាណក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-សហការជាមួយអង្គភាពនគរបាលទេសចរណ៍ក្នុងករណីមានការពាក់ព័ន្ធដល់កិច្ចការពារសុវត្ថិភាពជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងតំបន់ពាក់ព័ន្ធផ្សេងទៀត

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការណែនាំរបស់អគ្គនាយក អគ្គនាយករងទទួលបន្ទុក និងប្រធាន អ.ជ.ព.វ

-ធ្វើរបាយការណ៍សរុបតាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ ស្ដីពីសកម្មភាពការងាររបស់នាយកដ្ឋានសាមីប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ និងរបាយការណ៍ស្ដីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនិងការងាររបស់ខ្លួនជូនប្រធាន អ.ជ.ព.វ។

## ជំពូកទី ៥
## មូលនិធិបុរាណវិទ្យាប្រាសាទព្រះវិហារ

**មាត្រា ១៥.-**

ត្រូវបានបង្កើតគណនីពិសេសមួយមានឈ្មោះថា "មូលនិធិបុរាណវិទ្យាប្រាសាទព្រះវិហារ" ដើម្បីប្រមូលនិងទទួលយកមូលនិធិ ព្រមទាំងវិភាគទាន និងអំណោយពីសហគមន៍ជាតិ និងអន្តរជាតិសម្រាប់ជាប្រយោជន៍ក្នុងកម្មវិធីទ្រទ្រង់ប្រាសាទព្រះវិហារ ។

មូលនិធិបុរាណវិទ្យាប្រាសាទព្រះវិហារត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងប្រើប្រាស់របស់ប្រធាន អ.ជ.ព.វ ។

## ជំពូកទី ៦
## ការត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ១៦.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ០១ រូប អមអគ្គនាយកដ្ឋាននៃ អ.ជ.ព.វ. ដោយអនុលោមតាមអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាតាមក្រសួង និងគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ផ្នែក និងអង្គភាពដែលស្ថិតនៅក្រោមនាយកដ្ឋាននីមួយៗរបស់អគ្គនាយកដ្ឋាននៃ អ.ជ.ព.វ. ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន អ.ជ.ព.វ ដែលមានការឯកភាពពីអាណាព្យាបាលបច្ចេកទេសនៃ អ.ជ.ព.វ។

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានអ.ជ.ព.វ. អគ្គនាយកនៃអគ្គនាយកដ្ឋាន អ.ជ.ព.វ. អភិបាលខេត្ត ក្រុងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មករា ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា ១៩*

*-រាជកិច្ច*

*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគទីតាំងមន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង ទីតាំងមន្ទីរអប់រំ យុវជន និង កីឡា ខេត្តបាត់ដំបង និង ទីតាំង កងវរសេនាតូចលេខ៥១២ ចំណុះកងពលតូចថ្មើរជើងលេខ៥១

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-លិខិតលេខ ២១០ ស.ក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨ របស់ក្រសួងសាធារណការ និង ដឹកជញ្ជូន

-លិខិតលេខ ២៦៣ អយក ហវ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ របស់ក្រសួងអប់រំ យុវជន និង កីឡា

-របាយការណ៍លេខ២០៤/ប.ជ ២០០៧ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងការពារជាតិ

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងមន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង ទីតាំងមន្ទីរអប់រំ យុវជន និង កីឡា ខេត្តបាត់ដំបង និង ទីតាំងកងវរៈសេនាតូច លេខ៥១២ ចំណុះកងពលតូចថ្មើជើងលេខ៥១ ស្ថិតនៅឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដើម្បីធ្វើការផ្លាស់ប្តូរជាមួយផ្ទះទីតាំងថ្មី និង សំណង់ថ្មី របស់ភាគីឯកជន។

**មាត្រា ២.-**

ការកត់ត្រាទ្រព្យសម្បត្តិថ្មី របស់មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តបាត់ដំបង មន្ទីរអប់រំ យុវជន និង កីឡា ខេត្តបាត់ដំបង និង កងវរៈសេនាតូចលេខ៥១២ ចំណុះកងពលតូចថ្មើជើង លេខ៥១ ទៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសាធារណការ និង ដឹកជញ្ជូន ក្រសួងអប់រំ យុវជន និង កីឡា សាលាខេត្តបាត់ដំបង សាលាខេត្តបន្ទាយមានជ័យ និង មន្ទីរជំនាញពាក់ព័ន្ធចំណុះ ខេត្តបាត់ដំបង និង ខេត្តបន្ទាយមានជ័យ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា ៣.-**

ការបំពេញបែបបទផ្ទេរកម្មសិទ្ធិរបស់ភាគីឯកជន ទៅលើទីតាំងរបស់រដ្ឋ ដូចមានកំណត់នៅក្នុង មាត្រា ១ ត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ អភិបាលខេត្តបាត់ដំបង និង អភិបាលខេត្តបន្ទាយ មានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតក្រុមវិភាគព័ត៌មាន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើត ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានបង្កើត ក្រុមវិភាគព័ត៌មាន ដែលស្ថិតនៅក្រោមការណែនាំផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្រុមវិភាគព័ត៌មានត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាទីប្រឹក្សាផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អមដោយអនុប្រធាន និងសមាជិកដែលមានជំនាញ និងបច្ចេកទេសច្បាស់លាស់មួយចំនួន ។

សមាសភាពនៃក្រុមវិភាគព័ត៌មាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

ក្រុមវិភាគព័ត៌មាន មានតួនាទី និងភារកិច្ចដូចខាងក្រោមនេះ :

- តាមដាន ជ្រើសរើសព័ត៌មានសំខាន់ៗទាក់ទងនឹងព្រឹត្តិការណ៍ពិភពលោក ពិសេសព្រឹត្តិការណ៍ក្នុងតំបន់ដែលមានឥទ្ធិពលដល់ការពិចារណាក្នុងការធ្វើសេចក្តីសម្រេចខាងនយោបាយក្រៅប្រទេសរបស់រាជរដ្ឋាភិបាល
- ផ្តល់នូវទស្សនៈ ការវិភាគ និងធ្វើសំយោគអំពីព្រឹត្តិការណ៍ទាំងនោះ ដើម្បីបម្រើគោលដៅខាងលើនេះ
- ធ្វើការស្រាវជ្រាវ និងពន្យល់អត្ថន័យប្រវត្តិសាស្ត្រ ភូមិសាស្ត្រ-នយោបាយ និងយុទ្ធសាស្ត្រនៃបញ្ហា ឬព្រឹត្តិការណ៍លេចធ្លោនានាក្នុងលោក
- តាមដានអំពីការសរសេរ ការយល់ដឹង ការវាយតម្លៃអំពីកម្ពុជាលើសារព័ត៌មានអន្តរជាតិ និងក្នុងមជ្ឈដ្ឋានការទូត
- ទុកដាក់ រៀបចំ និងគ្រប់គ្រងឯកសារតាមប្រព័ន្ធកុំព្យូទ័រ និងតាក់តែងជំនួយស្មារតីជូនសម្តេចប្រមុខរាជរដ្ឋាភិបាលតាមការចាំបាច់
- ទាក់ទងការងារជាមួយគ្រប់ក្រសួងស្ថាប័ន រាប់ទាំងស្ថាប័នបរទេសផង ដើម្បីបុព្វហេតុស្រាវជ្រាវរបស់ខ្លួន
- បំពេញការងារផ្សេងទៀតតាមអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

ក្រុមវិភាគព័ត៌មានត្រូវប្រើប្រាស់ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុរបស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ។

ក្រុមវិភាគព័ត៌មានមានសិទ្ធិប្រើប្រាស់ត្រារបស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ។

**មាត្រា ៥.-**

ក្រុមវិភាគព័ត៌មានមានកញ្ចប់ថវិកាសម្រាប់ដំណើរការការងារក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៦
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី រាជការក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ២៣២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចរយៈពេលកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១ | លោក | **ញៀប ចាន់ណេ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ២ | លោក | **កេត ឈឿន** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៣ | លោកស្រី | **យ៉េង សំ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៤ | លោក | **មុំ ទីរះ** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ៥ | លោកស្រី | **ស្រ៊ី សេរីនី** | ប្រធានការិយាល័យពិធីការ |
| ៦ | លោកស្រី | **ម៉ែន សុគី** | ប្រធានការិយាល័យទំនាក់ទំនង |

| | | | |
|---|---|---|---|
| ៧ | លោកស្រី | ញៀប សុគាត | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៨ | លោក | ឆោ ខ្មៅ | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៩ | លោក | ហែម បូរ៉ា | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១០ | លោក | អ៊ួច គន្ធាធរ៉ា | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១១ | លោក | ឆិត ផេង | ប្រធានការិយាល័យលទ្ធកម្ម |
| ១២ | លោក | យស់ សំអុល | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ១៣ | លោក | លឹម អែលឡូរ៉េដូ | ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប |
| ១៤ | លោកស្រី | ម៉ៅ សូស្តី | ប្រធានការិយាល័យស្ថិតិ |
| ១៥ | លោកស្រី | ឋន្យ វិសេដ្ឋា | ប្រធានការិយាល័យផែនការ |
| ១៦ | លោក | ឈុន ហេង | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ១៧ | លោក | ឃួន ឡានិច | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ១៨ | លោកស្រី | ជី សុនា | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ១៩ | លោក | អ៊ុក សុខ | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ២០ | លោក | អ៊ឹង គៀវហេង | ប្រធានការិយាល័យរដ្ឋបាល |
| ២១ | លោក | តុប សំអ៊ី | ប្រធានការិយាល័យបុគ្គលិក |
| ២២ | លោកស្រី | ឆៀវ សារិន | អនុប្រធានការិយាល័យរដ្ឋបាល |
| ២៣ | លោក | មាស សុផាត | ប្រធានមណ្ឌលកុមារកំព្រាគៀនឃ្លាំង |
| ២៤ | លោកស្រី | ហុង លាងម៉េង | អនុប្រធានការិយាល័យថែទាំកុមារ |
| ២៥ | លោកស្រី | ចាន់ ហារ៉ាវន្ធី | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ |
| ២៦ | លោក | ទិត វ៉ាល់ដា | ប្រធានការិយាល័យ |
| ២៧ | លោក | អ៊ាង ជូ | ប្រធានការិយាល័យ |
| ២៨ | លោក | សាំង នៅ | អនុប្រធាននាយកដ្ឋានយុវនីតិសម្បទា |
| ២៩ | លោក | នួច សើរ | ប្រធានមណ្ឌលយុវនីតិសម្បទាចោមចៅ |
| ៣០ | លោក | ម៉ា ចំនួនណាត | អនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម |
| ៣១ | លោក | កែវ គីមថុន | អនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម |
| ៣២ | លោក | យក់ ឆេងហួរ | អនុប្រធានមន្ទីរ សអយ ខេត្តកោះកុង |
| ៣៣ | លោក | ចាន់ ហឿន | អនុប្រធានមន្ទីរ សអយ ខេត្តកំពង់ធំ |
| ៣៤ | លោក | អ៊ាប ឈុនស្រ៊ាង | ប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ |
| ៣៥ | លោក | ប៊ុន ខេន | ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក |

| | | | |
|---|---|---|---|
| ៣៦ | លោក | **មិន ថា** | ប្រធានការិយាល័យសោធននិវត្តន៍ |
| ៣៧ | លោក | **ឡេង ករុណា** | ប្រធានការិយាល័យសុខុមាលភាពកុមារ |
| ៣៨ | លោកស្រី | **ហេង ស្រីលំអូ** | ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក |
| ៣៩ | លោក | **ម៉ុក យ៉ាត** | អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក |
| ៤០ | លោក | **ដុំ ចាន់ថុល** | ប្រធានការិយាល័យសោធនអតីតយុទ្ធជន |
| ៤១ | លោកស្រី | **ឈា ម៉ានិត** | ប្រធានការិយាល័យសុខុមាលភាពកុមារ |
| ៤២ | លោក | **ធ្លាក់ សារ៉ែន** | ប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ |
| ៤៣ | លោក | **ពីង សារិត** | អនុប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ |
| ៤៤ | លោក | **សាត់ សាមឿន** | ប្រធានមន្ទីរ សអយ ក្រុងប៉ៃលិន |
| ៤៥ | លោក | **កែវ ភាន** | អនុប្រធានមន្ទីរ សអយ ក្រុងប៉ៃលិន |
| ៤៦ | លោក | **សុខ ហុន** | អនុប្រធានមន្ទីរ សអយ ខេត្តឧត្តរមានជ័យ |
| ៤៧ | លោក | **ឡាំ វណ្ណៈ** | អនុប្រធានមន្ទីរ សអយ ខេត្តស្វាយរៀង |
| ៤៨ | លោកស្រី | **ម៉ុន ពុទ្ធី** | អនុប្រធានមន្ទីរ សអយ ខេត្តកណ្តាល |
| ៤៩ | លោកស្រី | **ធ្លាក់ សាវ៉ាង** | អនុប្រធានមន្ទីរ សអយ ខេត្តកណ្តាល |
| ៥០ | លោកស្រី | **អ៊ួច ស៊ីណាត** | ប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ |
| ៥១ | លោកស្រី | **ស្វាយថុន មុនារិន្ទ** | ប្រធានការិយាល័យសុខុមាលភាពសង្គម |
| ៥២ | លោកស្រី | **ប៉ុល សុខលី** | អនុប្រធានមន្ទីរ សអយ ខេត្តកំពង់ស្ពឺ |

**ខ.មេដាយប្រាក់ការងារ :**

| | | | |
|---|---|---|---|
| ១ | លោកស្រី | **ឆន់ បូរិន** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប |
| ២ | លោក | **ឈឹម បូរ** | ប្រធានការិយាល័យបណ្ណាល័យ |
| ៣ | លោកស្រី | **ម៉េង គូម៉ារី** | អនុប្រធានការិយាល័យពិធីការ |
| ៤ | លោក | **រស់ ឆី** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ៥ | លោកស្រី | **ឈរ គីមអ៊ី** | ប្រធានការិយាល័យសំភារៈ |
| ៦ | លោកស្រី | **ចាន់ សុថារី** | ប្រធានការិយាល័យផ្គត់ផ្គង់ |
| ៧ | លោកស្រី | **ឃួន ឆវីវណ្ណ** | អនុប្រធានការិយាល័យហិរញ្ញវត្ថុ |
| ៨ | លោកស្រី | **ឆេព សុជាតា** | អនុប្រធានការិយាល័យ |
| ៩ | លោកស្រី | **ហុង សេឌី** | អនុប្រធានការិយាល័យ |
| ១០ | លោកស្រី | **ម៉ែន ម៉ាលីរតន៍** | អនុប្រធានការិយាល័យ |
| ១១ | លោកស្រី | **ជា សីដាលី** | អនុប្រធានការិយាល័យ |
| ១២ | លោក | **ជួរ រតនៈ** | អនុប្រធានការិយាល័យហិរញ្ញវត្ថុ |

| | | | |
|---|---|---|---|
| ១៣ | លោក | ទឹម និដ្ឋានុ | អនុប្រធានការិយាល័យ |
| ១៤ | លោក | អ៊ុក បូរ៉ា | អនុប្រធានការិយាល័យហិរញ្ញវត្ថុ |
| ១៥ | លោកស្រី | អាំ ចិន្តា | អនុប្រធានការិយាល័យ |
| ១៦ | លោក | សុខ លីវ៉ាមី | អនុប្រធានការិយាល័យ |
| ១៧ | លោកស្រី | ជួង សារ៉ាន់ | បុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១៨ | លោកស្រី | ហង្ស រ៉ា | បុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ |
| ១៩ | លោក | អ៊ំ សុខហេង | ប្រធានការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស |
| ២០ | លោកស្រី | ចែម សោភ័ណា | ប្រធានការិយាល័យសុំកូនចិញ្ចឹម |
| ២១ | លោកស្រី | ម៉ក់ ផាន់ណា | ប្រធានការិយាល័យថែទាំកុមារ |
| ២២ | លោក | សេក មុនី | អនុប្រធានការិយាល័យសុំកូនចិញ្ចឹម |
| ២៣ | លោកស្រី | ប៊ូ ស៊ីថា | អនុប្រធានការិយាល័យសេវាកម្មកុមារ និងគ្រួសារ |
| ២៤ | លោក | អ៊ុំ សុផាន់ណារ៉ា | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម |
| ២៥ | លោកស្រី | អ៊ុង វណ្ណឫទ្ធី | អនុប្រធាននាយកដ្ឋានសុខមាលភាពសង្គម |
| ២៦ | លោកស្រី | កែវ ម៉ាលី | អនុការិ.សេវាកម្មការពារជនផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ |
| ២៧ | លោក | ទ្រាំ ធន | អនុប្រធាននាយកដ្ឋានសោធននិវត្តន៍ |
| ២៨ | លោក | លុក ម៉ុនថា | ប្រធានការិយាល័យសេវាយុវនីតិសម្បទា |
| ២៩ | លោក | ចៅ ឆេង | ប្រធានការិយាល័យអភិវឌ្ឍកុមារ យុវកុមារ និងទណ្ឌិត |
| ៣០ | លោក | គង់ ឆុន | អនុប្រធានមណ្ឌលយុវនីតិសម្បទាចោមចៅ |
| ៣១ | លោក | មូល ឈន | ប្រធានមណ្ឌលជនពិការគៀនឃ្លាំង |
| ៣២ | លោក | ខូ ហួត | ប្រធានការិយាល័យស្តារកាយសម្បទា |
| ៣៣ | លោកស្រី | សុខ សាឡន | អនុប្រធានការិយាល័យស្តារកាយសម្បទា |
| ៣៤ | លោក | គង់ បូរិនសំគ្គ | អនុប្រធានការិ.បណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ |
| ៣៥ | លោក | លឹម ម៉េងហួរ | អនុប្រធានមន្ទីរ សអយ រាជធានីភ្នំពេញ |
| ៣៦ | លោក | យិន ចំរើន | ប្រធានមជ្ឈមណ្ឌលសង្គមកិច្ច |
| ៣៧ | លោក | នៅ ភារុន | ប្រធានការិយាល័យខ័ណ្ឌចំការមន |
| ៣៨ | លោកស្រី | យួន សុវណ្ណា | ប្រធានមជ្ឈមណ្ឌលសង្គ្រោះទារក |
| ៣៩ | លោក | ចាន់ សំអុន | ប្រធានការិយាល័យសោធននិវត្តន៍ខេត្តកំពង់ធំ |
| ៤០ | លោក | អ៊ុក សាវងលី | អនុប្រធានការិយាល័យសុខុមាលភាពកុមារ |
| ៤១ | លោក | អ៊ូ សាត | ប្រធានការិយាល័យស្រុកព្រះនេត្រព្រះ |
| ៤២ | លោកស្រី | តែ គឹមហ៊ាប | អនុប្រធានការិយាល័យសុខុមាលភាពសង្គម |

| | | | |
|---|---|---|---|
| ៤៣ | លោក | ជែត ចណ្ណា | អនុប្រធានមន្ទីរ សអយ ស្រុកព្រះសីហនុ |
| ៤៤ | លោកស្រី | ហេង សំអឿន | អនុប្រធានមន្ទីរ សអយ ក្រុងព្រះសីហនុ |
| ៤៥ | លោក | រ័ត្ន ពៅ | អនុប្រធានមន្ទីរ សអយ ខេត្តកំពត |
| ៤៦ | លោក | អាន លឹមគួយ | អនុប្រធានមន្ទីរ សអយ ខេត្តកំពត |
| ៤៧ | លោក | ឆេព ណារុន | ប្រធានការិយាល័យអតីតយុទ្ធជន |
| ៤៨ | លោក | លី សុខធី | អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក |
| ៤៩ | លោក | ឈុន នាង | អនុប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ |
| ៥០ | លោក | សន ថុងហោ | អនុប្រធានការិយាល័យហិរញ្ញវត្ថុ និងផែនការ |
| ៥១ | លោក | ម៉ៅ ម៉ុន | អនុប្រធានការិយាល័យអតីតយុទ្ធជន |
| ៥២ | លោក | ណាំ ហៃ | ប្រធានការិយាល័យគណនេយ្យ |
| ៥៣ | លោក | លុយ ហាក់ | ប្រធានការិយាល័យអតីតយុទ្ធជន |
| ៥៤ | លោក | ម៉ុល ពេល | ប្រធានការិយាល័យសុខុមាលភាពសង្គម |
| ៥៥ | លោកស្រី | ម៉ៅ សុខាណារី | អនុប្រធានមណ្ឌលកុមារកំព្រា |
| ៥៦ | លោក | សំ ម៉ុន | អនុប្រធានមន្ទីរ សអយ ខេត្តតាកែវ |
| ៥៧ | លោក | ប៊ី ជា | អនុប្រធានមន្ទីរ សអយ ខេត្តក្រចេះ |
| ៥៨ | លោក | សំហេង បុរស | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៥៩ | លោក | ឡុង ឆាំ | អនុប្រធានការិយាល័យអធិការកិច្ច |
| ៦០ | លោក | គឹង ហុង | ប្រធាននាយកដ្ឋានសោធនអតីតយុទ្ធជន |
| ៦១ | លោក | មាស ឈាន | អនុប្រធាននាយកដ្ឋានអភិវឌ្ឍអតីតយុទ្ធជន |

**គ_មេដាយសីវឌ្ឍការងារ :**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម | ប៊ុត ចំន្នដារ៉ាវុធ | ទីប្រឹក្សាអមក្រសួង |
| ២ | លោក | ហេង វង្សធីរិទ្ធ | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៣ | លោក | ហួត សាកល | ប្រធានការិយាល័យអ្នករជាតិ |
| ៤ | លោក | កើត ជឿន | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី |
| ៥ | លោក | សោម សារិន | ប្រធានមន្ទីរ សអយ ខេត្តព្រៃវែង |
| ៦ | លោក | អ៊ុន ស៊ីជេត | ប្រធានមន្ទីរ សអយ ខេត្តក្រចេះ |
| ៧ | លោក | យូ សុទ្ធី | អគ្គនាយករងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ |
| ៨ | លោក | សុន សៃ | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៩ | លោក | ទ្រាំ ឡេង | អធិការ |
| ១០ | លោកស្រី | ថេម សិខាមណី | ប្រធានការិយាល័យនីតិកម្ម |

| | | | |
|---|---|---|---|
